# របាយការណ៍ស្តីពីការចាប់ពិរុទ្ធការបោះពុម្ពផ្សាយលើអ៊ិនធឺណិតនៅកម្ពុជា ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២

## លទ្ធផលរកឃើញសំខាន់ៗ

ការវាស់វែងដោយក្រុមស្រាវជ្រាវ OONI ដែលប្រមូលបានពីខែមករាដល់ខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ បង្ហាញថា វ៉ិបសៃចំនួន៤៣ (វ៉ិបសៃរបស់អង្គការជាតិ និងអង្គការអន្តររដ្ឋាភិបាល) ត្រូវបានបិទខ្ទប់ដោយប្រព័ន្ធគ្រប់គ្រងឈ្មោះគេហទំព័រ (DNS) ភាគច្រើនដោយក្រុមហ៊ុនវៀតថែល (ខេមបូឌា) ភីធីអ៊ី.អិលធីឌី (AS38623) និង S.I Group (AS38623)។ វ៉ិបសៃដែលរងផលប៉ះពាល់ទាំងនេះ ស្ថិតក្នុងប្រភេទផ្សេងៗ រួមមានបញ្ហាសិទ្ធិមនុស្ស ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ការរិះគន់ខាងនយោបាយ បណ្តាញសង្គម ការចែករំលែកសំណុំឯកសារ ល្បែងស៊ីសង អ្នកស្រលាញ់ភេទដូចគ្នា គ្រឿងស្រវឹង និងគ្រឿងញៀន និងអង្គការអន្តររដ្ឋាភិបាល។

- វ៉ិបសៃដែលបង្កើតឡើងសម្រាប់ការពិភាក្សាអំពីបញ្ហាសិទ្ធិមនុស្ស ក្នុងទម្រង់ផ្សេងៗ រួមទាំងសិទ្ធិស្រ្តី និងសិទ្ធិរបស់ក្រុមជនជាតិភាគតិច។
- អង្គការសារព័ត៌មានជាតិ និងតំបន់ (ដែលភាគច្រើនជាសំឡេងឯករាជ្យ ឬរិះគន់)
- បញ្ហាផ្សេងៗរបស់អ្នកស្រលាញ់ភេទដូចគ្នា - ស្រ្តីស្រឡាញ់ភេទដូចគ្នា - ប្រុសស្រឡាញ់ប្រុស - អ្នកកែភេទ ឬអ្នកស្រឡាញ់ភេទដូចគ្នា។
- ការលេងល្បែងស៊ីសង និងការចែករំលែកសំណុំឯកសារ

វ៉ាត់ស៍អាប (WhatsApp) មេសិនជ័រហ្វេសប៊ុក (Facebook Messenger) និងបណ្តាញ Tor ហាក់ដូចជាអាចចូលប្រើបាននៅទូទាំងបណ្តាញទាំងអស់ដែលបានសាកល្បង ពេញអំឡុងពេលសាកល្បង ហើយលទ្ធផលបានបង្ហាញថា មិនមានការចាប់ពិរុទ្ធទេ។

# សេចក្តីផ្តើម

វិបសៃព័ត៌មាន និងវិបសៃផ្សេងទៀត ត្រូវបានបិទតាមកាលកំណត់នៅក្នុងប្រទេសកម្ពុជា ជាពិសេសវិបសៃដែលផ្សព្វផ្សាយព័ត៌មាន ដែលគេយល់ឃើញថា ជាការគំរាមកំហែងដល់រដ្ឋាភិបាលដែលកំពុងកាន់អំណាច[1]។ នៅក្នុងខែកក្កដា ឆ្នាំ២០១៨ រដ្ឋាភិបាលបានបញ្ជាឱ្យអ្នកផ្តល់សេវាអ៊ិនធឺណិត (ISP) បិទវិបសៃព័ត៌មានយ៉ាងតិច១៥ ក្នុងអំឡុងពេលបោះឆ្នោតនៅក្នុងប្រទេស[2]។ បន្ទាប់ពីមានការរាតត្បាតជំងឺកូវីដ-១៩ មានសេចក្តីរាយការណ៍ថា រដ្ឋាភិបាលបានបិទការចូលប្រើវិបសៃព័ត៌មាន[3]។ ។ នៅក្នុងខែមិថុនា ឆ្នាំ២០២០ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (MPTC) បានបិទវិបសៃល្បែងស៊ីសងអនឡាញចំនួនប្រាំមួយ[4]។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២១ និយតករទូរគមនាគមន៍កម្ពុជា (TRC) បានបិទវិបសៃល្បែងស៊ីសងខុសច្បាប់ចំនួន៧៩[5] ។ នៅក្នុងខែធ្នូ ឆ្នាំ២០២១ និយតករទូរគមនាគមន៍កម្ពុជាបានបិទវិបសៃ និង URL ចំនួន៩ ដែលបង្ហោះរូបភាព និងវីដេអូអាសអាភាសកុមារ[6]។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២២ និយតករទូរគមនាគមន៍កម្ពុជាបានបិទវិបសៃឆ្នោតខុសច្បាប់ចំនួន១៥[7] ។

ក្នុងការប៉ុនប៉ង ដើម្បីពិនិត្យស្ថានភាពបច្ចុប្បន្ននៃការចាប់ពិរុទ្ធលើអ៊ិនធឺណិតនៅកម្ពុជា អង្គការឃ្លាំមើលការជ្រៀតជ្រែកបណ្តាញបើកចំហ (OONI) គម្រោង Sinar និងវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយបានសហការគ្នាលើការសិក្សារួមគ្នាមួយ ដើម្បីពិនិត្យមើលថា តើហេតុការណ៍ចាប់ពិរុទ្ធលើអ៊ិនធឺណិតនៅតែបន្តកើតមាននៅក្នុងប្រទេសនេះដែរទេ តាមរយៈការប្រមូលទិន្នន័យ និងវិភាគការវាស់វែងបណ្តាញ។

គោលបំណងនៃការសិក្សានេះ គឺដើម្បីបង្កើនតម្លាភាពនៃការត្រួតត្រាអ៊ិនធឺណិត និងប្រមូលទិន្នន័យដែលអាចជាអំណះអំណាងបញ្ជាក់ពីពាក្យចចាមអារ៉ាម និងរបាយការណ៍អំពីហេតុការណ៍ចាប់ពិរុទ្ធលើអ៊ិនធឺណិត។ ផ្នែកខាងក្រោមនៃរបាយការណ៍នេះ ផ្តល់ព័ត៌មានអំពីទេសភាពបណ្តាញ និងកម្រិតនៃការចូលប្រើអ៊ិនធឺណិតរបស់កម្ពុជា បរិយាកាសផ្លូវច្បាប់របស់វា ទាក់ទងនឹងសេរីភាពនៃការបញ្ចេញមតិ សិទ្ធិទទួលបានព័ត៌មាន និងឯកជន

---

[1] https://freedomhouse.org/country/cambodia/freedom-net/2021#footnote1_q5lblmn

[2] https://www.voacambodia.com/a/government-confirm-blocking-fifteen-independent-news-sites-over-poll-disruption/4503739.html

[3] https://freedomhouse.org/country/cambodia/freedom-net/2021#footnote1_q5lblmn

[4] https://freedomhouse.org/country/cambodia/freedom-net/2021#footnote1_q5lblmn

[5] Cambodia Blocks 79 Online Gambling Websites (freshnewsasia.com)

[6] Telecom regulator of Cambodia blocks 9 websites and URL that posted child pornographic images and videos - Khmer Times (khmertimeskh.com)

[7] Cambodia blocks 15 illegal lottery websites (focusgn.com)

ភាព ក៏ដូចជាព័ត៌មានអំពីករណីនៃការចាប់ពិរុទ្ធ និងការស៊ើបការណ៍ដែលត្រូវបានរាយការណ៍ពីមុនៗ នៅក្នុងប្រទេស។ ក្រៅពីនេះ របាយការណ៍នេះកត់ត្រាលទ្ធផលរកឃើញសំខាន់ៗនៃការសិក្សានេះ។

## សាវតារ

ជាសង្គមដែលមានវ័យចំណាស់នៅតំបន់អាស៊ីអាគ្នេយ៍ ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីទំហំ ១៨១,០៣៥ គីឡូម៉ែត្រការ៉េ (ស្មើនឹង៦៩,៨៩៨ ម៉ាយល៍ការ៉េ) មានព្រំប្រទល់ជាប់ប្រទេសថៃ ឡាវ វៀតណាម និងឈូងសមុទ្រថៃ និងមានប្រជាជនចំនួន១៦,៧៨ លាននាក់ ស្ត្រីមានចំនួន៥១% ។ ប្រជាជនភាគច្រើនមានដើមកំណើតជាតិជាខ្មែរ ដែលស្មើនឹង ៩០% នៃប្រជាជនសរុប បន្ទាប់ពីខ្មែរ គឺជនជាតិវៀតណាម ដែលមានចំនួន៥% ជនជាតិភាគតិចមានចំនួន៤% និងជនជាតិចិនមានចំនួន១%។ ព្រះពុទ្ធសាសនាត្រូវបានទទួលស្គាល់ជាផ្លូវការថាជាសាសនារបស់រដ្ឋ ដែលក្នុងនោះប្រជាជនជាង ៩៧% បដិបត្តិព្រះពុទ្ធសាសនាថេរវាទ។ សាសនាផ្សេងទៀតរួមមានសាសនាឥស្លាម សាសនាគ្រិស្ត និងជំនឿព្រលឹងវិញ្ញាណរបស់កុលសម្ព័ន្ធ។

បន្ទាប់ពីការឈ្លានពានរបស់វៀតណាម រដ្ឋាភិបាលកុម្មុយនិស្តថ្មីដែលបានលើកបន្តុបនៅដើមឆ្នាំ១៩៧៩ បានគ្រប់គ្រងប្រទេសអស់រយៈពេលជាងមួយទសវត្ស ហូតដល់ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យលើកដំបូងត្រូវបានរៀបចំនៅក្នុងឆ្នាំ១៩៩៣។ ការបោះឆ្នោតនេះត្រូវបានគ្រប់គ្រង និងចាត់ចែងដោយក្រុមប្រឹក្សារក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដែលហៅថាអ៊ុនតាក់ (អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា) ដែលមានគណបក្សនយោបាយចំនួន ៤៨ បានចូលរួម រាប់ទាំងភាគីជម្លោះទាំង ៤ផង។ រដ្ឋាភិបាលចម្រុះត្រូវបានបង្កើតឡើង និងដឹកនាំដោយនាយករដ្ឋមន្ត្រីពីររូប មួយរូបមកពីគណបក្សកុម្មុយនិស្តដ៏យូរលង់គឺ គណបក្សប្រជាជនកម្ពុជា (CPP) និងមួយរូបមកពីគណបក្សរាជានិយម ហ្វ៊ុនស៊ិនប៉ិច (រណសិរ្សរួបរួមជាតិ ដើម្បីកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព និងសហប្រតិបត្តិការ)។

អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដែលមិនរឹងមាំបាននាំឱ្យព្រះរាជាណាចក្រធ្លាក់ចូលក្នុងរដ្ឋប្រហារនៅឆ្នាំ១៩៩៧ ជិតដល់ពេលបញ្ចប់ដំណាក់កាលចុងក្រោយនៃរដ្ឋាភិបាលអាណត្តិដំបូង។ ការបោះឆ្នោតជាតិជាបន្តបន្ទាប់ក្រោយមកទៀតមួយចំនួន ដែលគ្រប់គ្រងចាត់ចែងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបានរៀបចំឡើង ប៉ុន្តែត្រូវបានគេយល់ឃើញថា មានការលម្អៀង និងមិនមានសេរីភាពរួចផុតពីឥទ្ធិពល។ ដោយអនុវត្តប្រព័ន្ធបញ្ជីគណបក្ស ការបោះឆ្នោតលើកកម្ពស់គណនេយ្យភាពរបស់អ្នកតំណាងជាប់ឆ្នោតចំពោះ

គណបក្សនយោបាយរបស់ខ្លួន ជាជាងមណ្ឌលបោះឆ្នោត។ មនោគមវិជ្ជានយោបាយបែបនេះត្រូវបានបង្កប់នៅក្នុងគ្រប់រចនាសម្ព័ន្ធអភិបាលកិច្ចនៅថ្នាក់ភូមិ ថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ មានការរិះគន់កាន់តែច្រើនចំពោះឯករាជ្យភាពរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងស្ថាប័នតុលាការចំពោះគណបក្សនយោបាយ ដែលភាគច្រើនជាគណបក្សកាន់អំណាច។

អង្គការសង្គមស៊ីវិល (CSO) បានធ្វើការយ៉ាងស្វាហាប់ ដើម្បីកាត់បន្ថយភាពក្រីក្រសម្រាប់សហគមន៍ជនបទ និងសហគមន៍ដែលរងផលប៉ះពាល់ បង្កើនផលិតភាពកសិកម្ម បង្កើនការអភិវឌ្ឍន៍សេដ្ឋកិច្ច លើកកម្ពស់សមធម៌ និងសមភាពយេនឌ័រ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ព្រមទាំងជំរុញលទ្ធិប្រជាធិបតេយ្យ និងលើកកម្ពស់សិទ្ធិមនុស្ស។ ពួកគេធ្វើការជាតំណាងនៅក្នុងវិស័យផ្សេងៗ ដើម្បីទាមទារឱ្យមានគោលនយោបាយ និងការអនុវត្តដែលមានការឆ្លើយតប ពីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ។ ចាប់ពីឆ្នាំ២០១២ មក អ្នកសារព័ត៌មាន អង្គការសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្ស (HRD) បានចាប់យកអិនធឺណិត ដើម្បីធ្វើការតស៊ូមតិ និងផ្សព្វផ្សាយការងាររបស់ខ្លួន។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) និងច្បាប់ស្តីពីសារពើពន្ធត្រូវបានអង្គការសង្គមស៊ីវិល និងអ្នកជំនាញមួយចំនួន យល់ឃើញថាជាឧបករណ៍របស់រដ្ឋាភិបាល ក្នុងការរឹតត្បិតអង្គការមិនមែនរដ្ឋាភិបាលដែលហ៊ានរិះគន់រដ្ឋាភិបាល និងគណបក្សកាន់អំណាច ជាពិសេសអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការតស៊ូមតិ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនរួមមានវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ត្រូវបានបិទ ឬបង្ខំឱ្យបិទដោយរដ្ឋាភិបាល។

ស្ថាប័នសារព័ត៌មានមួយចំនួន រួមមានស្ថានីយ៍ទូរទស្សន៍ និងស្ថាប័នវិទ្យុភាគច្រើន ត្រូវបានតម្រែតម្រង់ឱ្យស្របជាមួយគណបក្សកាន់អំណាច[8] ឬរដ្ឋាភិបាល។ ស្ថាប័នសារព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាលដែលរឹងមាំ និងឯករាជ្យមួយចំនួន ជួបបញ្ហានៅក្នុងប្រតិបត្តិការរបស់ខ្លួន ក្រោមលក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់ LANGO និងច្បាប់ស្តីពីសារពើពន្ធ ជាពិសេស។ រដ្ឋាភិបាលរងការរិះគន់ថា បានបង្កើនការត្រួតត្រាលើទេសភាពប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេស។ ភ្លាមៗក្រោយការរំលាយគណបក្សប្រឆាំង ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិមួយ

[8] វិទ្យុសេរីរបស់ក្រុមប្រឆាំងត្រូវបានបិទនៅកម្ពុជា| DW Learn German

ចំនួនដែលភាគច្រើនមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ត្រូវបានបិទដោយបង្ខំដោយរដ្ឋាភិបាល។ ប្រព័ន្ធផ្សព្វផ្សាយទាំងនោះ អាចផ្សាយបានតែកម្មវិធីអនឡាញរបស់ខ្លួន ពីបរទេសប៉ុណ្ណោះ។

ភាពសកម្មបានលេចឡើងក្នុងទសវត្សចុងក្រោយនេះ។ អ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន និងសកម្មជនកសិករ មានភាពលេចធ្លោនៅក្នុងកិច្ចការនយោបាយរបស់ប្រទេស ដោយបានធ្វើការទាមទារឱ្យមានការឆ្លើយតប និងគណនេយ្យភាពពីរដ្ឋាភិបាលចំពោះសង្គម និងមណ្ឌលបោះឆ្នោត ខណៈដែលអ្នកសារព័ត៌មានពលរដ្ឋបានក្លាយជាអ្នកមានឥទ្ធិពលខ្លាំង នៅក្នុងវិស័យសារព័ត៌មាននៅមូលដ្ឋាន។ ចលនា និងទំនាក់ទំនងបុគ្គលផ្ទាល់ខ្លួន និងការប្រាស្រ័យទាក់ទងតាមអនឡាញរបស់ពួកគេ ស្ថិតក្រោមការឃ្លាំមើល ឬការស៊ើបការណ៍ពីរដ្ឋាភិបាលកាន់តែខ្លាំងឡើង។ អ្នកសារព័ត៌មាន សកម្មជន និងអ្នកប្រើប្រាស់អ៊ិនធឺណិតផ្សេងទៀត ប្រឈមមុខនឹងការរុកគួនផ្លូវកាយ និងតាមអនឡាញកាន់តែខ្លាំង ចំពោះការបង្ហោះតាមអនឡាញរបស់ពួកគេ។ អ្នកសារព័ត៌មានខ្មែរ លោក កូវ ពិសិដ្ឋ កំពុងប្រឈមមុខនឹងការកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ៥ឆ្នាំ បន្ទាប់ពីលោកបានបង្ហោះការរិះគន់នៅលើហ្វេសប៊ុក អំពីការសម្រេចចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការប្រើប្រាស់ថ្នាំបង្ការស៊ីណូហ្វាម និងស៊ីណូវ៉ាក់របស់ប្រទេសចិន កាលពីថ្ងៃទី២៧ ខែមិថុនា[9]។

រដ្ឋាភិបាលបានអះអាងថា កម្ពុជា ជាប្រទេសដែលមានប្រាក់ចំណូលទាបក្នុងឆ្នាំ២០១៥ ហើយនឹងក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៣០។ ការអះអាងនេះបាននាំឱ្យមានការផ្លាស់ប្តូរចំពោះទេសភាពហិរញ្ញប្បទាន។ វាបានបង្កប់នូវការជំពាក់ជំពិននៅក្នុងចលនាងាកចេញពីសហគមន៍អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយបស្ចិមប្រទេស ខណៈបង្ហាញពីការហូរចូលនៃកម្មវិធី និងកម្ចីពីប្រទេសចិនសម្រាប់ការអភិវឌ្ឍ និងការលើកកម្ពស់ធុរកិច្ច។ ការអភិវឌ្ឍអ៊ិនធឺណិតរបស់ប្រទេស មានការកើនឡើងខ្លាំងក្នុងរយៈពេលតែប៉ុន្មានឆ្នាំប៉ុណ្ណោះ។ ក្រុមហ៊ុន IPS ចំនួនប្រាំកំពុងវិនិយោគកាន់តែច្រើនឡើង នៅក្នុងអាជីវកម្មដែលកំពុងរីកលូតលាស់យ៉ាងគំហុកនេះ។ ក្រុមហ៊ុនទាំងអស់នេះមានប្រភពមកពីប្រទេសកុម្មុយនិស្ត និងផ្តាច់ការ ជារួមគឺប្រទេសចិន និងវៀតណាម។

---

[9] ប្រទេសកម្ពុជា៖ អ្នកសារព័ត៌មានក្នុងស្រុករងការចោទប្រកាន់ពីបទញុះញង់ដោយសារបានបង្ហោះសារអំពីថ្នាំបង្ការ - សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)

រដ្ឋាភិបាលបានអះអាងថា ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិតបានបង្កបញ្ហាប្រឈម និងការគំរាមកំហែងយ៉ាងខ្លាំងដល់សុវត្ថិភាព និងសន្តិសុខជាតិ។ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខជាតិ រដ្ឋាភិបាលបានខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការតាក់តែង និងដាក់ឱ្យអនុវត្តច្បាប់ និងបទដ្ឋានគត់យុត្តិទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ និងអ៊ិនធឺណិត។ ផ្ទុយទៅវិញ ច្បាប់ និងបទដ្ឋានគតិយុត្តិទាំងនេះ ត្រូវបានរិះគន់ថា ជាឧបករណ៍ ដើម្បីបង្កើនការឃ្លាំមើល ឬស៊ើបការណ៍ការងាររបស់អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងសកម្មជនដែលហ៊ានរិះគន់រដ្ឋាភិបាល និងគណបក្សកាន់អំណាច។

## ទេសភាពបណ្តាញ និងការចូលប្រើអ៊ិនធឺណិត

តាមរយៈទំនាក់ទំនង និងឥទ្ធិពលដ៏រឹងមាំរបស់ខ្លួនលើ ISP រដ្ឋាភិបាលបានពង្រីកការត្រួតត្រារបស់ខ្លួនលើអ៊ិនធឺណិត។ ដូចបានបញ្ជាក់ សេរីភាពអ៊ិនធឺណិតនៅកម្ពុជាកំពុងស្ថិតក្រោមការគំរាមកំហែងកាន់តែខ្លាំង។ ក្រុមហ៊ុនទូរគមនាគមន៍ធំៗចំនួនប្រាំ កំពុងផ្តល់សេវាអ៊ិនធឺណិតកប់ដី និងចល័តនៅក្នុងប្រទេសកម្ពុជា គឺក្រុមហ៊ុនវៀតថែល (Viettel) ស្មាត អាកស៊ាតា (Smart Axiata) ខែមជីអេសអឹម (CamGSM) ស៊ិនវ៉េ (Xinwei) តេលេខម (Telecom) និងអាស៊ីអាគ្នេយ៍ទូរគមនាគមន៍ (Southeast Asia Telecom) ដែលសុទ្ធតែមានប្រភពមកពីប្រទេសដែលប្រើអំណាចផ្តាច់ការ។ ការគ្រប់គ្រងរបស់ពួកគេមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា (RGC) និងមន្ត្រីរបស់ខ្លួន ហើយពួកគេទំនងជាផ្តល់ការធានារ៉ាប់រងគ្នាទៅវិញទៅមក នៅពេលដែលមានការពិនិត្យពិច័យជាសាធារណៈ[10]។ ដូចបានកំណត់ដោយច្បាប់ស្តីពីទូរគមនាគមន៍ ISPs ត្រូវតែមានអាជ្ញាប័ណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

មានឧបករណ៍ទំនាក់ទំនងដែលលេចធ្លោចំនួនបីនៅក្នុងប្រទេសកម្ពុជាគឺ ទូរស័ព្ទចល័ត ទូរស័ព្ទអចល័ត និងអ៊ិនធឺណិត។ យោងតាមនិយតករទូរគមនាគមន៍កម្ពុជា ដែលទើបដំណើរការថ្មីៗ ចំនួនអតិថិជនដែលប្រើប្រាស់ទូរស័ព្ទអចល័ត បានថយចុះពី២២៧,២៦១ នាក់ក្នុងឆ្នាំ២០១៦ មកនៅត្រឹម ៣៩,២៧២ នាក់នៅក្នុងឆ្នាំ២០២២ (ខែឧសភា)។ ការប្រើប្រាស់ទូរស័ព្ទចល័តមានស្ថេរភាពជាមធ្យម ដោយបានថយចុះបន្តិចពី១៩.៩១

[10] សេរីភាពអ៊ិនធឺណិតនៅកម្ពុជា៖ ប្រកទ្វារសម្រាប់ត្រួតត្រា (asiacentre.org)

លាននាក់ ក្នុងឆ្នាំ២០១៦ មកដល់១៩.៤៨ លាននាក់ ក្នុងខែឧសភា ឆ្នាំ២០២២[11]។ ទោះជាយ៉ាងនេះក្តី ការចូលប្រើអ៊ិនធឺណិតបានកើនឡើងយ៉ាងគំហុកក្នុងរយៈពេល៧ ឆ្នាំ។ វាបានកើនឡើងពី៨.០៩ លាននាក់ ក្នុងឆ្នាំ ២០១៦ ដល់១៨.០០ លាននាក់ ក្នុងខែឧសភា ឆ្នាំ២០២២។ គួរកត់សម្គាល់ថា មនុស្សម្នាក់អាចជាវប្រើបណ្តាញលើសពីមួយ។

## អ្នកជាវប្រើបណ្តាញចល័ត




| | 2022 (May) | 2021 | 2020 | 2019 | 2018 | 2017 | 2016 |
|---|---|---|---|---|---|---|---|
| Mobile Subscriber | 19,483,052 | 19,899,790 | 20,827,435 | 21,675,523 | 19,417,123 | 18,572,973 | 19,915,503 |
| Fixed Phone Subscriber | 39,272 | 40,296 | 49,381 | 57,438 | 88,157 | 132,911 | 227,261 |
| Internet Subscriber | 18,003,898 | 17,872,173 | 20,340,480 | 16,126,356 | 13,611,398 | 10,649,370 | 8,099,132 |

ប្រភព៖ និយតករទូរគមនាគមន៍កម្ពុជា

## ការផ្ញើសាររហ័ស

ដោយផ្អែកលើទិន្នន័យដែលអាចរកបាន សេវាអ៊ិនធឺណិតថេរបានកើនឡើងបន្តិចពី២៨៣,៥០៨ ក្នុងឆ្នាំ២០២១ ដល់៣១២,២៣៣ ក្នុងឆ្នាំ២០២២ (ខែឧសភា)។

បណ្តាញផ្សព្វផ្សាយសង្គមត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យដែលផ្តល់ជូន នៅក្នុងតារាងខាងក្រោម បង្ហាញថា នៅដើមឆ្នាំ២០២២ ហ្វេសប៊ុកមានអ្នកប្រើប្រាស់ចំនួន១១.៦០ លាននាក់

---

[11] ទោះជាយ៉ាងណា អ្នកប្រើប្រាស់ភាគច្រើនប្រើប្រាស់ទូរស័ព្ទចល័តចម្រុះ ជាមួយបណ្តាញច្រើនផ្សេងៗគ្នា (មិត្តហ្វូន ស៊ែលកាត ស្មាត,...) ដូច្នេះ វាមិនមែនជាសញ្ញាដ៏មានប្រយោជន៍ដែលបង្ហាញថា ម្រាមដៃនៃការប្រើប្រាស់ទូរស័ព្ទចល័ត មានច្រើនជាងចំនួនប្រជាជនទេ។

មេស៊្សិនជើហ្វេសប៊ុកបានកើនឡើងដល់៧.៨៥ លាននាក់នៅក្នុងប្រទេសកម្ពុជា[12]។ បន្ទាប់ពីហ្វេសប៊ុក និងមេស៊្សិនជើហ្វេសប៊ុក គឺអ៊ិនស្តាក្រាម ដែលមានអ្នកប្រើប្រាស់ចំនួន២.០៥ លាននាក់ ស្មើនឹង១២.០ ភាគរយនៃប្រជាជនសរុប ហើយចំនួនអ្នកប្រើប្រាស់បណ្តាញតិកតុកបានកើនដល់ដល់៦.៦៨ លាននាក់។ ទោះបីជាយ៉ាងនេះក្តី បណ្តាញដែលមានអ្នកប្រើតិចតួចបំផុត គឺលីងឌិន (LinkedIn) ក៏ត្រូវបានប្រើប្រាស់នៅក្នុងប្រទេសនេះផងដែរ[13]។

| ឆ្នាំ | មេស៊្សិនជើហ្វេសប៊ុក | អ្នកប្រើហ្វេសប៊ុក | អ៊ិនស្តាក្រាម | តិកតុក | លីងឌិន |
|---|---|---|---|---|---|
| ២០២២ | ៧.៨៥ លាននាក់ | ១១.៦០ លាននាក់ | ២.០៥លាននាក់ | ៦.៦៨លាននាក់ | ៤៦០ ពាន់នាក់ |

ប្រភព៖ datareportal

## ក្រុមហ៊ុនទូរស័ព្ទចល័ត

យោងតាមនិយតករទូរគមនាគមន៍កម្ពុជា ក្រុមហ៊ុនចំនួនបី (មិត្តហ្វូន ស៊ែលកាត និងស្មាត) នៃក្រុមហ៊ុនទូរគមនាគមន៍ទាំងប្រាំ មានអ្នកប្រើប្រាស់ចំនួន៩០%។ មិត្តហ្វូនមានសេវាគ្របដណ្តប់ធំជាងគេលើទិន្នន័យទូរសព្ទចល័ត និងការប្រើប្រាស់អ៊ីនធឺណិត ប៉ុន្តែស៊ែលកាតបានឈ្នះពានរង្វាន់ Ookla Speed Test Award រយៈពេល៤ ឆ្នាំ ចាប់ពីឆ្នាំ២០១៧ ដល់២០២០។ ស្មាតមានកេរ្តិ៍ឈ្មោះល្បីល្បាញតាមរយៈការលើកកម្ពស់ការចាប់ផ្តើមអាជីវកម្មបច្ចេកវិទ្យាសម្រាប់យុវជន និងក្មេងជំទង់។ ជាពិសេស ស៊ែលកាត និងស្មាត ផ្តល់ជូនការផ្សព្វផ្សាយជាច្រើន កីឡាអេឡិចត្រូនិក និងហ្គេមអេឡិចត្រូនិក ដែលទទួលបានការចាប់អារម្មណ៍ពីយុវជន។

| ល.រ | បណ្តាញ | ក្រុមហ៊ុន |
|---|---|---|
| ១ | ស្មាត | ស្មាត អាស៊ាតា ខូ.អិលធីឌី (Smart Axiata Co., Ltd) |
| ២ | ម៉ូបីថែល/ស៊ែលកាត | ខែមជីអេសអឹម ខូ.អិលធីឌី (CamGSM Co., Ltd) |

[12] ប៉ុន្តែ វាជាការសំខាន់ ក្នុងការកត់សម្គាល់ថា អ្នកប្រើបណ្តាញផ្សព្វផ្សាយសង្គមអាចមិនតំណាងឱ្យបុគ្គលដោយឡែកៗទេ។
[13] https://datareportal.com/reports/digital-2022-cambodia

| | | |
|---|---|---|
| ៣ | យូថែល | ស៊ីវ៉េ (ខេមបូឌា) ថេឡេខម ខូ.អិលធីឌី (Xinwei (Cambodia) Telecom Co., Ltd) |
| ៤ | ស៊ីថែល (SEATEL) | សារអ៊ីស អេស៊ា ថេឡេខម ខូ.អិលធីឌី (Southeast Asia Telecom (Cambodia) Co., Ltd) |
| ៥ | មិត្តហ្វូន (Metfone) | វៀតថែល (ខេមបូឌា) ភីធីអ៊ី.អិលធីឌី (Viettel (Cambodia) Pte., Ltd) |

ប្រភព៖ និយតករទូរគមនាគមន៍កម្ពុជា

# អ្នកផ្តល់សេវាអ៊ិនធឺណិត

ដោយមានអាជ្ញាប័ណ្ណពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អ្នកផ្តល់សេវាអ៊ិនធឺណិតជិត ៣០ បានដំណើរការនៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមអ្នកផ្តល់សេវាទាំងនោះ មានក្រុមហ៊ុនទូរគមនាគមន៍ធំៗចំនួន៥ ដែលផ្តល់ទាំងសេវាអ៊ិនធឺណិតក្រោមដី និងតាមទូរសព្ទចល័តគឺៈ ក្រុមហ៊ុនវៀតថៃល ស្មាត អាកស៊ាតា ខេមជីអេសអឹម ក្រុមហ៊ុនស៊ិនវ៉េ ថេឡេខម និងថេឡេខម អាស៊ីអាគ្នេយ៍ ដែលសុទ្ធតែមានប្រភពចេញពីប្រទេសដែលប្រើអំណាចផ្តាច់ការ។ វៀតថៃល ជាក្រុមហ៊ុនវៀតណាម ដែលគ្រប់គ្រងដោយក្រសួងការពារជាតិនៃប្រទេសវៀតណាម ធ្វើប្រតិបត្តិការនៅកម្ពុជា ក្រោមឈ្មោះមិត្តហ្វូន។

ក្រុមហ៊ុនខេមជីអេសអឹមត្រូវបានគេស្គាល់ពីដំបូងថា ម៉ូប៊ីថែល មុនពេលប្តូរឈ្មោះជា ស៊ែលកាតនៅក្នុងឆ្នាំ ២០០៥។ ក្រុមហ៊ុនវៀតថេល ស្មាតអាកស៊ាតា និងខេមជីអេសអឹមក្នុងស្រុក មានចំណែកជិត៩០% នៃចំណែកទីផ្សារនៃការជាវប្រើទូរសព្ទចល័ត។ ក្រុមហ៊ុនស្មាតអាកស៊ាតាទទួលបានចំណែកទីផ្សារជិត៦០% ខណៈវៀតថៃលទទួលបានចំណែកទីផ្សារចំនួន២៦% និងខេមជីអេសអឹមទទួលបានចំណែកទីផ្សារចំនួន១១%។ ក្រុមហ៊ុនស៊ិនវ៉េ ថេឡេខម មកពីប្រទេសចិន ដែលធ្វើប្រតិបត្តិការក្រោមឈ្មោះ ឃូថៃល និងថេឡេខម អាស៊ីអាគ្នេយ៍មកពីប្រទេសសិង្ហបុរី មានចំណែកទីផ្សារចំនួន២.៦៧% និង ០.៦៥% ដោយឡែកៗពីគ្នា[14]។ ជាពិសេស មិត្តហ្វូនកំពុងផ្តល់សេវាគ្រប់ប្រភេទ (ការចូលប្រើអ៊ិនធឺណិត ជួលខ្សែបណ្តាញ ជួលសៀគ្វីឯកជន សេវាផ្ញើសារជាសំឡេង និងសារទូរស័ព្ទ, ADSL) ខណៈ អ្នកផ្តល់សេវាអ៊ិនធឺណិតផ្សេងទៀតក៏ផ្តល់សេវាមួយចំនួនក្នុងចំណោមសេវាទាំងនេះផងដែរ។

| ល.រ | ឈ្មោះអ្នកផ្តល់សេវាអ៊ិនធឺណិត | ASNs |
|---|---|---|
| ១ | អនឡាញ | 23673<br>24325 |
| ២ | អង្គរណេិត (AngkorNet) | 24478 |
| ៣ | អ៊ីហ្ស៊ីខម (EZECOM) | 38901 |
| ៤ | មិត្តហ្វូន (MetFone) | 38623 |

[14] សេរីភាពអ៊ិនធឺណិតនៅកម្ពុជាៈ ច្រកទ្វារសម្រាប់ត្រួតត្រា (asiacentre.org)

| | | |
|---|---|---|
| ៥ | ឃ្លិកណិត ( Clicknet ) | 38893 |
| ៦ | តេឡេសឺហ្វ/ម៉ូប៊ីថែល ( TeleSURF / Mobitel ) | 17976 |
| ៧ | វ៉ាយខែម ( WiCam ) | 24492 |
| ៨ | ខែមណិត ( CamNet ) | 17726 |
| ៩ | ឈួន វ៉េ ( Chuan Wei ) | 45348 |
| ១០ | ស៊ីធី លីង ( City Link ) | 18014<br>24441 |
| ១១ | កាំមីនតែល ( Camintel ) | 38209 |
| ១២ | មេគង្គណិត ( MekongNet ) | 131186<br>131203 |
| ១៣ | ស្មាត ម៉ូបាល ( Smart Mobile ) | 45498 |
| ១៤ | មេគង្គណិត អាយអិកភី ( MekongNet IXP ) | 38235 |
| ១៥ | វ៉ាយអឺឡែសអាភី ( WirelessIP ) | 24567 |
| ១៦ | ប៊ីយ៉ន់ថែល ( BeyondTel ) | 45339 |
| ១៧ | ស៊ីអាយឌីធី អាយធី ( CIDC IT ) | 7712 |
| ១៨ | ខេមបូ បច្ចេកវិទ្យា ( Cambo Technology ) | 17981 |
| ១៩ | ឌីធីវី ស្តា ( DTV Star ) | 45429 |
| ២០ | ហេឡូ ( Hello ) | 38600 |

| | | |
|---|---|---|
| | | 45281 |
| ២១ | នីអូខមអាយអេសភី (NeocomISP) | 9902<br>23868 |
| ២២ | ភីភីស៊ីធីវី (PPCTV) | 38286 |
| ២៣ | ហ្វាញឌ័រ អាយអិកភី (Finder IXP) | 45124 |
| ២៤ | ស្តា-សែល (Star-Cell) | 38723 |
| ២៥ | ហ្វ្លាស់ ថិច (Flash Tech) | 45465 |
| ២៦ | អូផិនណិត (Opennet) | 131178 |
| ២៧ | អេស.អាយ ណិត (S.I Net) | 131207 |
| ២៨ | ស៊ីប៊ី (CB) | 38579 |

# បរិយាកាសផ្នែកច្បាប់

ជាយុត្តិកម្មសម្រាប់ការលើកកម្ពស់កិច្ចការពារសុវត្ថិភាព និងសន្តិសុខជាតិ រដ្ឋាភិបាលកម្ពុជាបានព្រាង អនុម័ត និង/ឬដាក់ឱ្យអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តិច្បាប់មួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ទាំងនេះបានរងការរិះគន់ថាជាឧបករណ៍របស់រដ្ឋាភិបាល ដែលត្រូវបានប្រើប្រាស់ ដើម្បីបង្កើនការត្រួតត្រាលើការប្រើប្រាស់អិនធឺណិត ដែលកំពុងប៉ះពាល់ដល់សិទ្ធិសេរីភាពជាមូលដ្ឋាននៃការបញ្ចេញមតិ។

# សេរីភាពខាងការបញ្ចេញមតិ

## រដ្ឋធម្មនុញ្ញ

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញធានាសេរីភាពខាងការបញ្ចេញមតិ។ ទោះជាយ៉ាងណាក៏ដោយ មាត្រា៤១ ចែងថា ក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ "ជនណាក៏ដោយមិនអាចឆ្លៀតប្រើប្រាស់សិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះ

ពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ”។ ដូចមានភស្តុតាងបង្ហាញនៅក្នុងច្បាប់ជាតិ និងវិធានការមិនមែនច្បាប់ក្រោយៗមក រដ្ឋបានប្រកាសឱ្យប្រើយ៉ាងសកម្មនូវវិធានការនានា ដើម្បីកាត់បន្ថយការជានាសេរីភាពអ៊ិនធឺណិត ដោយផ្អែកលើកង្វល់ទាំងឡាយទាក់ទងនឹងកិត្តិយស សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ។ មាត្រា៤១ ក៏ចែងអំពីនិយតកម្មលើប្រព័ន្ធផ្សព្វផ្សាយ៖ «របបសារព័ត៌មានត្រូវកំណត់ដោយច្បាប់»។

វិសោធនកម្មចុងក្រោយនៃរដ្ឋធម្មនុញ្ញ ក្នុងឆ្នាំ២០១៨ បានកាត់បន្ថយថែមទៀតនូវការអនុលោមតាមស្តង់ដារអន្តរជាតិ។ វិសោធនកម្មមាត្រា៤៩ ទាក់ទងនឹងការគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ និងការការពារជាតិ មានចរិតបង្កគ្រោះថ្នាក់ដល់សេរីភាពជាមូលដ្ឋានខ្លាំងបំផុត។ វិសោធនកម្មពេលនេះកំណត់កាតព្វកិច្ចឱ្យ “ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតែម្កល់ផលប្រយោជន៍ជាតិជាធំ” ហើយមិនត្រូវ “ធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរឡើយ”។ នៅពេលធ្វើយុត្តិកម្មបង្ហាញពីភាពចាំបាច់ដែលតម្រូវឱ្យធ្វើវិសោធនកម្មនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានហៅចំសកម្មជន អ្នកការពារសិទ្ធិមនុស្ស និងសមាជិកគណបក្សប្រឆាំង ដែលបានធ្វើការអំពាវនាវសុំឱ្យសហគមន៍អន្តរជាតិ ដាក់ទណ្ឌកម្មមកលើកម្ពុជា ជុំវិញការបង្ក្រាបរបស់រដ្ឋាភិបាលលើគណបក្សប្រឆាំង និងសង្គមស៊ីវិល (Nachemson & Dara, ឆ្នាំ២០១៨)។ នៅក្នុងបរិបទបែបនេះ វាបង្ហាញយ៉ាងប្រចក្សថា មាត្រា៤៩ ដែលត្រូវបានធ្វើវិសោធនកម្មនេះ អាចត្រូវបានប្រើប្រាស់យ៉ាងងាយស្រួល ដើម្បីរារាំងសេរីភាពខាងការបញ្ចេញមតិតាមអ៊ិនធឺណិត ជាពិសេសនៅពេលដែលមានការថ្លែងរិះគន់រដ្ឋ ឬសង្កត់ធ្ងន់លើការអំពាវនាវឱ្យមានចំណាត់ការប្រឆាំងនឹងរដ្ឋ។ រាល់ការប្រឆាំងជំទាស់នឹងរដ្ឋាភិបាល អាចនាំឱ្យមានវិធានការច្បាប់មិនសមាមាត្រភ្លាមៗ ដាក់ទោសទណ្ឌលើការអនុវត្តសេរីភាពខាងការបញ្ចេញមតិ[15]។

## ក្រមព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានបញ្ញត្តិដែលប្រើពាក្យពេចន៍មិនច្បាស់លាស់អំពី "ការរួមគំនិតក្បត់" ការចែករំលែក "ព័ត៌មានមិនពិត" និង "ការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍" ដែលត្រូវបានប្រើ ដើម្បីចោទប្រកាន់អ្នកប្រើប្រាស់អ៊ិនធឺណិត ចំពោះការបង្ហោះ និងចែករំលែកខ្លឹមសាររិះគន់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ បទល្មើសបរិហារកេរ្តិ៍ ត្រូវបានបញ្ញត្តិក្រោមមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ លើសពីនេះ ការផ្សព្វផ្សាយព័ត៌មានមិនពិត និងសន្និដ្ឋិភាព ត្រូវផ្តន្ទាទោសក្រោមមាត្រា៤២៥ និង៤៥៣ ខណៈច្បាប់ពាក់ព័ន្ធនឹងបទ

[15] Government looks to make controversial amendments to Constitution | Phnom Penh Post cited in សេរីភាពអ៊ិនធឺណិតនៅកម្ពុជា៖ ច្រកទ្វារដើម្បីត្រួតពិនិត្យ (asiacentre.org)

ញុះញង់ និងបង្កឱ្យប្រព្រឹត្តបទឧក្រិដ្ឋមានចែងក្នុងមាត្រា៤៩៤ និង៤៩៥ ។ វិសោធនកម្មចុងក្រោយនៅក្នុងឆ្នាំ ២០១៨ បានដាក់បញ្ចូលមាត្រា៤៣៧ *ស្ទួន* ឬបញ្ញត្តិស្តីពីការប្រមាថព្រះមហាក្សត្រ ក្នុងក្រមនេះ។

មាត្រា៣០៥ ស្តីពីបទបរិហារកេរ្តិ៍ជាសាធារណៈ ចែងថា "គ្រប់ការអះអាងបំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឲ្យប៉ះពាល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន" គឺជាការបរិហារកេរ្តិ៍"។ បទបរិហារកេរ្តិ៍អាចត្រូវបានប្រព្រឹត្តតាមមធ្យោបាយជាច្រើន។ ប្រភេទនៃការបរិហារកេរ្តិ៍នៅក្នុងការវាយតម្លៃនេះ អនុវត្តចំពោះគ្រប់បទប្បញ្ញត្តិដែលបានចែងនៅក្នុងផ្នែកនេះ និងគ្របដណ្តប់សកម្មភាពទូទៅរបស់អ្នកប្រើប្រាស់តាមអនឡាញភាគច្រើន ដូចជាការសរសេរ និងការចែករំលែកការបង្ហោះនៅលើវេទិកាអនឡាញ ឬបណ្តាញផ្សព្វផ្សាយសង្គម។ ប្រសិនបើអំពើតាមអនឡាញទាំងនេះត្រូវបានចាត់ទុកថាជាការបរិហារកេរ្តិ៍ អំពើនេះនឹងត្រូវផ្តន្ទាទោសដោយការផាកពិន័យពី២៤.៦០ ដុល្លារ ទៅ២៤៦060 ដុល្លារអាមេរិក។ មាត្រា៣០៥ រួមជាមួយបទប្បញ្ញត្តិផ្សេងទៀតក្នុងក្រមព្រហ្មទណ្ឌនេះ ត្រូវបានប្រើប្រាស់ដោយមិនសមាមាត្រ ដើម្បីបំបិទមាត់សម្លេងរិះគន់របស់អ្នកនយោបាយគណបក្សប្រឆាំង និងអ្នករិះគន់។

មាត្រា៤២៥ (បទក្លែងព័ត៌មាន) ផ្តន្ទាទោស "អំពើផ្តល់ ឬបើកកកាយព័ត៌មានក្លែង ដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោម ឬការធ្វើឱ្យខូចខាតប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស"។ បញ្ញត្តិនេះត្រូវបានអាជ្ញាធរមូលដ្ឋានប្រើប្រាស់ ក្នុងការផ្តន្ទាទោសលើការផ្សព្វផ្សាយព័ត៌មានដែលពួកគេយល់ថាជាការក្លែងព័ត៌មាន រួមទាំងមតិរិះគន់សំដៅលើទៅរដ្ឋាភិបាលដែលពួកគេជឿថាអាចបង្កអស្ថិរភាពនយោបាយឬធ្វើឱ្យខូចខាតដល់កេរ្តិ៍ឈ្មោះរបស់ពួកគេ។ ការប្រើប្រាស់មាត្រានេះដើម្បីផ្តន្ទាទោសបុគ្គលណាម្នាក់ អាចនាំឱ្យមានការជាប់ពន្ធនាគារពីមួយឆ្នាំទៅពីរឆ្នាំ ឬពិន័យជាប្រាក់ពី ៤៩0 ដុល្លារ ទៅ៩៨១ ដុល្លារអាមេរិក។

ដូចគ្នានេះដែរ មាត្រា៤៥៣ សន្និដ្ឋិភាព និងបទរួមគំនិតក្បត់ប្រឆាំងនឹងរដ្ឋាភិបាល ផ្តន្ទាទោស "គម្រោងដែលបង្កើតឡើងដោយមនុស្សច្រើននាក់ ដើម្បីប្រព្រឹត្តឧបឃាត កាលបើគម្រងនេះត្រូវបានសម្តែងចេញជារូបរាងច្បាស់លាស់ ដើយអំពើជាក់ស្តែងមួយ ឬច្រើន ជាបទសន្និដ្ឋិភាព"។ បុគ្គលដែលត្រូវបានចោទប្រកាន់ អាចប្រឈមមុខនឹងការជាប់ពន្ធនាគារពីប្រាំឆ្នាំ ទៅដប់ឆ្នាំ។ មាត្រានេះត្រូវបានគេប្រើប្រាស់មិនបានត្រឹមត្រូវ ក្នុងការផ្តន្ទាទោសអ្នកប្រឆាំងនឹងរដ្ឋ សូម្បីតែក្នុងករណីដែលគ្មានភស្តុតាងបញ្ជាក់អំពីអំពើរួមគំនិតក្បត់។

បទប្បញ្ញត្តិដែលត្រូវបានប្រើជាញឹកញាប់បំផុត ដើម្បីធ្វើទុក្ខមុកម្នេញសមាជិកគណបក្សប្រឆាំង អ្នករិះគន់រដ្ឋាភិបាល សកម្មជន និងអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយ គឺមាត្រា៤៩៤ និង៤៩៥ (បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍)។ យោងតាមមាត្រា៤៩៥ "បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់

សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងក្នុងមាត្រា៤៩៤ ដូចគ្នានឹងបញ្ញត្តិនៃមាត្រា៣០៥ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ ខែ ទៅ២ ឆ្នាំ និងពិន័យជាប្រាក់ពី១ លាន ទៅ៤ លានរៀល ប្រសិនបើការញុះញង់នេះ គ្មានប្រសិទ្ធភាពទេ»។

មាត្រា៤៣៧ *ស្ទួន* (បទប្រមាថព្រះមហាក្សត្រ) ហាមប្រាមការរិះគន់ព្រះមហាក្សត្រ និងកំណត់ការផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី ៥០០ ដុល្លារអាមេរិក ទៅ ២.៤៦០ ដុល្លារអាមេរិក។ ដោយអនុវត្តតាមការនាំមុខរបស់ប្រទេសថៃ ក្នុងការកាត់ទោសអ្នករិះគន់នយោបាយពីបទប្រមាថព្រះមហាក្សត្រ បញ្ញត្តិនេះរំលោភបំពានលើសេរីភាពអនឡាញរបស់អ្នកប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គម (Boyle and Chhengpor, ឆ្នាំ២០១៨)។ អ្នកប្រើអ៊ីនធឺណិតអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនេះតាមរយៈ "ពាក្យសម្តី កាយវិការ ការសរសេរ រូបភាព ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល"[16]។

## ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

នៅខែមេសា ឆ្នាំ២០២០ រដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិក្នុងភាពអាសន្ន ដើម្បីឆ្លើយតបទៅនឹងការរាតត្បាតជំងឺកូវីដ-១៩។ ច្បាប់នេះតបានទទួលរងការរិះគន់យ៉ាងខ្លាំងពីសង្គមស៊ីវិល ចំពោះការផ្តល់ឱ្យរដ្ឋាភិបាលនូវអំណាចទូលំទូលាយ ក្នុងការរឹតត្បិតសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ក្នុងអំឡុងពេលស្ថានភាពអាសន្ន[17]។ ច្បាប់នេះបានផ្តល់អំណាចដល់រដ្ឋាភិបាល ក្នុងការពិនិត្យតាមដានព័ត៌មានតាមអនឡាញ ហាមឃាត់ ឬរឹតបន្តឹងការចែករំលែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ និងអនុវត្តវិធានការផ្សេងទៀតដែលខ្លួនយល់ថាចាំបាច់[18]។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរៀបចំព្រះរាជក្រឹត្យសម្រាប់ព្រះមហាក្សត្រប្រើប្រាស់ ប្រសិនបើព្រះអង្គសម្រេចប្រកាសដាក់ប្រទេសជាតិក្នុងភាពអាសន្ន បន្ទាប់ពីមានការរីករាលដាលជំងឺកូវីដ-១៩ ក្នុងខែវិច្ឆិកា ឆ្នាំ ២០២០។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលមិនបានប្រកាសដាក់ប្រទេសជាតិក្នុងភាពអាសន្នជាផ្លូវការទេ ក្នុងអំឡុងពេលគ្របដណ្តប់[19]។

## សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានឆ្នាំ២០១៩

---

16 សេរីភាពអ៊ិនធឺណិតនៅកម្ពុជា៖ ច្រកទ្វារ ដើម្បីត្រួតពិនិត្យ (asiacentre.org)

17 https://cchrcambodia.org/index_old.php?title=Civil-Society-Organizations-call-for-the-Royal-Government-of-Cambodia-to-Amend-the-State-of-Emergency-Law-to-Protect-Human-Rights&url=media/media.php&p=press_detail.php&prid=756&id=5&lang=eng cited in https://freedomhouse.org/country/cambodia/freedom-net/2021#footnote5_03c1n4i

18 https://www.justsecurity.org/71194/opportunism-covid-19-and-cambodias-state-of-emergency-law/ cited in https://freedomhouse.org/country/cambodia/freedom-net/2021#footnote5_03c1n4i

19 https://freedomhouse.org/country/cambodia/freedom-net/2021#footnoteref7_ackf8i0

ដោយមានការការពារសម្រាប់អ្នករាយការណ៍ព័ត៌មាន និងមានសក្តានុពលក្នុងការជះឥទ្ធិពលជាវិជ្ជមានលើសេរីភាពនៃការបញ្ចេញមតិតាមអនឡាញ ប្រសិនបើត្រូវបានអនុម័ត និងអនុវត្ត សេចក្តីព្រាងដែលបានចេញផ្សាយជាសាធារណៈនៅក្នុងខែសីហា ឆ្នាំ២០១៩ បានលើកឡើងពីការព្រួយបារម្ភអំពីអនុលោមភាពនៃច្បាប់ ទៅនឹងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជាការប្រើប្រាស់ស្តង់ដារដែលទូលំទូលាយ និងមិនច្បាស់លាស់នៅក្នុងច្បាប់នេះ ដែលអាចគំរាមកំហែងដល់ការទទួលបានព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ។ ឧទាហរណ៍ ច្បាប់នេះកំណត់យ៉ាងចង្អៀតអំពីប្រភេទព័ត៌មាន និងស្ថាប័នដែលច្បាប់នេះត្រូវអនុវត្ត ខ្វះខាតនីតិវិធីត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព អនុញ្ញាតឱ្យអាជ្ញាធរសាធារណៈបដិសេធការលាតត្រដាងព័ត៌មាននៅក្នុងស្ថានភាពដែលទូលំទូលាយពេក និងមានបទប្បញ្ញត្តិបទបរិហារកេរ្តិ៍ និងបទបរិហារបង្ខូចកេរ្តិ៍។ នៅក្នុងខែសីហា ឆ្នាំ២០២០ ច្បាប់នេះត្រូវបានបញ្ចប់ និងត្រូវបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច[20]។ ក៏ប៉ុន្តែ ដោយសារការពន្យារពេលដែលបណ្តាលមកពីការរាតត្បាតជំងឺកូវីដ-១៩ ច្បាប់នេះមិនទាន់ត្រូវបានបញ្ជូនទៅរដ្ឋសភា រហូតដល់ចុងឆ្នាំ២០២១[21]។

## ច្បាប់ស្តីពីទូរគមនាគមន៍

ច្បាប់ស្តីពីទូរគមនាគមន៍ឆ្នាំ២០១៥ កំណត់កាតព្វកិច្ចទូទៅលើអ្នកផ្តល់សេវាទូរគមនាគមន៍ ដែលអាជ្ញាធរអះអាងថា នឹងលើកកម្ពស់ការទទួលបានសេវានៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងក្របខ័ណ្ឌលិខិតគតិយុត្តដ៏ធំទូលាយ ច្បាប់នេះក៏មានមុខងារជាឧបករណ៍ផ្លូវច្បាប់ ដើម្បីតាមដានសកម្មភាពលើអ៊ិនធឺណិតដែរ។ សេរីភាពនៃការបញ្ចេញមតិត្រូវបានគំរាមកំហែងតាមរយៈការអនុវត្តមន្ត្រីអធិការកិច្ចទូរគមនាគមន៍ (មាត្រា៧០ និង៧១) ការធ្លាក់ចុះនៃការការពារទិន្នន័យ (មាត្រា៩៧ និង៦) និងការផ្តន្ទាទោសសេរីភាពនៃការបញ្ចេញមតិតាមវិទ្យុ ទូរទស្សន៍ អនឡាញ និងក្នុងសារឯកជន (មាត្រា៨០)។

មាត្រា៦ តម្រូវឱ្យ "គ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍" ផ្តល់ "ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា" ទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។ ការខ្វះនិយមន័យអំពីអ្នកដែលមានសិទ្ធិអំណាចស្របច្បាប់នេះ បង្កឱ្យមានភាពចម្រូងចម្រាស់យ៉ាងខ្លាំង និងអាចនាំឱ្យមានការស៊ើបការណ៍តាមអំពើចិត្ត។ ដូច្នេះ ច្បាប់នេះ - ដោយអនុញ្ញាតឱ្យមានការស៊ើបការណ៍ឧបករណ៍អេឡិចត្រូនិច - អាចបង្កលក្ខ

[20] https://freedomhouse.org/country/cambodia/freedom-net/2021#footnote8_m0ohwpo
[21] https://www.ifj.org/media-centre/news/detail/category/press-releases/article/cambodia-government-needs-to-pass-access-to-information-law.html

ណៈងាយស្រួលដល់អាជ្ញាធរកម្ពុជា ក្នុងការថតសម្លេងតាមទូរស័ព្ទ និងតាមដានការសន្ទនាតាមអនឡាញយ៉ាងសកម្ម ដើម្បីធ្វើទុក្ខបុកម្នេញ**បុគ្គលដែលត្រូវបានកំណត់ជាគោលដៅ**

មាត្រា៨០ ចែងថា "ការបង្កើត ការដំឡើង និងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារក្នុងវិស័យទូរគមនាគមន៍ កាលបើអំពើនេះនាំឲ្យអន្តរាយដល់សន្តិសុខជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ ឆ្នាំ ទៅ១៥ ឆ្នាំ"។ ការខ្វះភាពច្បាស់លាស់លើប្រភេទនៃសកម្មភាពទូរគមនាគមន៍អាចដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរលើការបញ្ចេញមតិស្របច្បាប់តាមរយៈកម្មវិធីវិទ្យុ ទូរទស្សន៍ អនឡាញ និងសូម្បីតែតាមរយៈសារឯកជន និងការសន្ទនាតាមទូរស័ព្ទរវាងបុគ្គលប្រសិនបើអាជ្ញាធរកំណត់ថាវាជាការគំរាមកំហែង[22]។

## ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមអ៊ិនធឺណិត (សេចក្តីព្រាង)[23]

ដោយបានស្នើនៅក្នុងឆ្នាំ២០១២ ច្បាប់នេះត្រូវធ្វើការកែប្រែបន្ថែមទៀត ដើម្បីឱ្យឆ្លើយតបទៅនឹងប្រតិកម្មរិះគន់ ហើយគិតត្រឹមខែសីហា ឆ្នាំ២០២១ មិនទាន់មានការកំណត់កាលបរិច្ឆេទដាក់លាក់សម្រាប់ការបញ្ចប់សេចក្តីព្រាង ឬសម្រាប់ការអនុវត្តច្បាប់នេះទេ។ មាត្រា៨ និងមាត្រា១២ ចែងថា អ្នកផ្តល់សេវាត្រូវតែ "រក្សាទុកទិន្នន័យចរាចរណ៍រយៈពេល១៨០ ថ្ងៃ យ៉ាងតិច" ដើម្បីចែករំលែកជាមួយ "អាជ្ញាធរមានសមត្ថកិច្ច" នៅពេលមានការស្នើសុំ។

មាត្រា៣២ និង៣៣ ផ្តន្ទាទោសចំពោះ "ការចូលប្រើដោយគ្មានការអនុញ្ញាត" ទៅក្នុងប្រព័ន្ធកុំព្យូទ័រ ឬការផ្ទេរទិន្នន័យពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀតដោយគ្មានការអនុញ្ញាត។ ជនដែលត្រូវបានចោទប្រកាន់តាមមាត្រាទាំងនេះត្រូវប្រឈមនឹងការជាប់ពន្ធនាគាររហូតដល់១០ ឆ្នាំ។ មាត្រាទាំងនេះក៏បង្កឱ្យមានក្តីកង្វល់ដល់អ្នករាយការណ៍ព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដែលចូលប្រើព័ត៌មានបែបនេះ ដើម្បីលាតត្រដាងអំពីការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយរដ្ឋផងដែរ ដោយសារមាត្រាទាំងនេះមិនបានចែងអំពីការការពារគ្រប់គ្រាន់។

មាត្រា៤០ ផ្តន្ទាទោសការប្រើប្រាស់កុំព្យូទ័រ ដើម្បីផ្តួចផ្តើម "ការរំខាន ការភ័យខ្លាច ការគំរាមកំហែង ការបំពាន [និង] ការបំភិតបំភ័យ"។ ជនដែលត្រូវបានចោទប្រកាន់តាមមាត្រានេះ ប្រឈមនឹងការជាប់ពន្ធនាគារយ៉ាងយូរប្រាំមួយខែ។ មាត្រា៤៥ ផ្តន្ទាទោស "ជនទាំងឡាយណាដែលធ្វើសេចក្តីថ្លែងការណ៍មិនពិត ឬការបំភាន់ជាសម្ភា

---

[22] TITLE PAGE (licadho-cambodia.org) ដកស្រង់នៅក្នុង សេរីភាពអ៊ិនធឺណិតនៅកម្ពុជា៖ ប្រកទ្វារ ដើម្បីត្រួតពិនិត្យ (asiacentre.org)

[23] សេរីភាពអ៊ិនធឺណិតនៅកម្ពុជា៖ ប្រកទ្វារ ដើម្បីត្រួតពិនិត្យ (asiacentre.org)

រៈតាមរយៈ ព័ត៌មានវិទ្យា” ដែលអាចនាំឱ្យអន្តរាយដល់ “សុវត្ថិភាពសាធារណៈ” និង “សន្តិសុខជាតិ”។

## សេរីភាពពីការជ្រៀតជ្រែក

សេរីភាពសារព័ត៌មាន និងសេរីភាពអ៊ិនធឺណិតនៅកម្ពុជា កំពុងទទួលរងការគំរាមកំហែងកាន់តែខ្លាំង។ នៅក្នុងរបាយការណ៍ "សេរីភាពក្នុងពិភពលោក" ឆ្នាំ២០២២ ដោយអង្គការផ្ទះសេរីភាព (Freedom House) ប្រទេសកម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រទេស "មិនមានសេរីភាព"។ ប្រជាជនមិនហ៊ានបញ្ចេញទស្សនៈ ឬមតិតាមអនឡាញ ជាពិសេសអ្នកដែលហ៊ានរិះគន់រដ្ឋាភិបាល។ រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ច្បាប់ និងលិខិតគតិយុត្តិដែលមានស្រាប់ និងបង្កើតច្បាប់ថ្មី ដើម្បីបង្កើនការជ្រៀតជ្រែក។ មានការកត់សម្គាល់ថា ក្រមព្រហ្មទណ្ឌត្រូវបានប្រើប្រាស់នៅក្នុងករណីពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន ហើយច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ត្រូវបានប្រើប្រាស់ក្នុងករណីពាក់ព័ន្ធនឹងអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។

ក្នុងឆ្នាំ២០២០ រដ្ឋាភិបាលបានអនុម័តច្បាប់ ដើម្បីប្រកាសភាពអាសន្ន ដែលផ្តល់សិទ្ធិអំណាចដ៏ច្រើនលើសលប់ដល់អាជ្ញាធរ ក្នុងការធ្វើប្រតិបត្តិការស៊ើបការណ៍តាមឌីជីថល ហាមប្រាមការប្រមូលផ្តុំ និងហាមប្រាម ឬកម្រិតការផ្សាយ ក្នុងចំណោមបទប្បញ្ញត្តិផ្សេងទៀតដែលស្ទើរតែស្មើនឹងអំណាចដែលគ្មានការត្រួតពិនិត្យ។ ដូចបានកត់សម្គាល់ដោយអង្គការផ្ទះសេរីភាព ខណៈដែលមិនបានប្រកាសភាពអាសន្ន រដ្ឋាភិបាលបានចេញការគំរាមកំហែងជាច្រើន នៅពេលដែលជំងឺរាតត្បាតសកលបានលេចចេញជារូបរាង ហើយមនុស្សមួយចំនួនរួមទាំងប្រជាពលរដ្ឋទូទៅ និងអ្នកដែលគេចាត់ទុកជាអ្នកនយោបាយប្រឆាំងត្រូវបានចាប់ខ្លួនពេញមួយឆ្នាំ ក្រោមលេសថា ពួកគេបានផ្សព្វផ្សាយព័ត៌មានមិនពិតអំពីជំងឺកូវីដ-១៩ ឬមានចេតនាបំពានការពិពណ៌នាអំពីសុខភាពសាធារណៈរបស់រដ្ឋាភិបាល។ នៅក្នុងឆ្នាំ២០២១ មនុស្សរាប់សិបនាក់ត្រូវបានចាប់ខ្លួនពីបទរិះគន់ការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះជំងឺរាតត្បាតកូវីដ-១៩។

យោងតាមការសិក្សាថ្មីៗនេះរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR) ដែលបានធ្វើការស្ទង់មតិអ្នកសារព័ត៌មានចំនួន ៣៥ នាក់ បានបង្ហាញថា អ្នកសារព័ត៌មានបានទទួលរងការជ្រៀតជ្រែក។ អ្នកឆ្លើយសំណួរគ្រប់រូបបានរាយការណ៍ថា ពួកគេបានប្រឈមមុខនឹងទម្រង់នៃការជ្រៀតជ្រែកមួយចំនួន ខណៈពេលកំពុងបំពេញការងារ។ ទម្រង់នៃការជ្រៀតជ្រែកដែលទូទៅបំផុត គឺការឈ្លបយកការណ៍ ឬការឃុំខ្លួនដោយបំពាន។ កំណត់ត្រារបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ

ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានបង្ហាញថា គិតត្រឹមខែឧសភា ឆ្នាំ២០២២ មានការឃុំខ្លួនដោយបំពានដោយឡែកៗពីគ្នា ចំនួន៤៣២៣ លើក នៅក្នុងបរិបទនៃកូដកម្មនៅកាស៊ីណូណាហ្គាវើល។ កំណត់ត្រាមួយទៀតរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានរាយការណ៍ថា ចាប់តាំងពីខែមករា ឆ្នាំ២០១៧ អ្នកសារព័ត៌មានចំនួន២៣ នាក់បានប្រឈមមុខនឹងការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ដោយសារការបំពេញការងាររបស់ខ្លួន។ នៅក្នុងរបាយការណ៍ថ្មីៗរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា មានការសន្និដ្ឋានថា អ្នកសារព័ត៌មាននៅកម្ពុជាទទួលរងការបៀតបៀន និងសម្ពាធក្នុងទម្រង់ផ្សេងៗ ក៏ដូចជាអំពើហិង្សា កាន់តែច្រើនឡើង ខណៈមានការរឹតត្បិតកាន់តែតឹងរឹងលើលំហពលរដ្ឋ និងសេរីភាពសារព័ត៌មាននៅក្នុងប្រទេស។

## សេរីភាពពីការចាប់ពិរុទ្ធ

ការចាប់ពិរុទ្ធបានកើនឡើងយ៉ាងគំហុកនៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តាមរយៈទម្រង់ផ្សេងៗគ្នា។ ការដាក់ឱ្យអនុវត្តដោយបង្ខំវិធានការផ្លូវច្បាប់ និងមិនមែនផ្លូវច្បាប់ដោយរដ្ឋាភិបាលកម្ពុជាប្រឆាំងនឹងក្រុម ឬបុគ្គលដែលត្រូវបានកំណត់ជាគោលដៅ បានរឹតត្បិតជាអវិជ្ជមានចំពោះការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពអ៊ិនធឺណិត។

[ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា] បានធ្វើអំណះអំណាងថា ខណៈប្រកាសលេខ១៧០ និងអនុក្រឹត្យស្តីពីច្រកទ្វារអ៊ិនធឺណិតជាតិ កំណត់គោលដៅជាពិសេសទៅលើប្រព័ន្ធផ្សព្វផ្សាយ ផលប៉ះពាល់ដែលអាចកើតមាននៃឧបករណ៍ទាំងនេះលើសេរីភាពនៃការបញ្ចេញមតិជារួម និងសេរីភាពសារព័ត៌មានជាពិសេស មានលក្ខណៈជ្រាលជ្រៅ។ ឧបករណ៍ទាំងពីរនេះផ្តល់អំណាចដាច់ខាតយ៉ាងទូលំទូលាយនៅក្នុងរដ្ឋាភិបាល ក្នុងការចាប់ពិរុទ្ធការបញ្ចេញមតិក្នុងលក្ខណៈដែលហាក់ដូចជាហួសពីអ្វីដែលត្រូវបានអនុញ្ញាតដោយមាត្រា ១៩(៣) នៃកតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បង្កើតស្ថានភាពដែលអនុញ្ញាតឱ្យភ្នាក់ងាររដ្ឋាភិបាលមានសិទ្ធិអំណាចក្នុងការចាប់ពិរុទ្ធការបញ្ចេញមតិ និងការរាយការណ៍ ដែលពួកគេយល់ថា មានបញ្ហា។ ដោយឆ្លុះបញ្ចាំងពីបញ្ជារបស់ក្រសួងព័ត៌មាន ឱ្យអ្នកផ្តល់សេវាអ៊ិនធឺណិត បិទខ្ទប់សេវារបស់ស្ថាប័នផ្សព្វផ្សាយ ឬវិបសៃព័ត៌មានឯករាជ្យចំនួន១៥ ក្នុងអំឡុងពេលបោះឆ្នោតជាតិកាលពីឆ្នាំ ២០១៨ មានការអះអាងថា ប្រកាសលេខ១៧០ និងអនុក្រឹត្យស្តីពីច្រកទ្វារអ៊ិនធឺណិតជាតិ គំរាមកំហែងផ្តល់ មូលដ្ឋាននីតិកម្មផ្លូវការបន្ថែមទៀតសម្រាប់ការបិទវិបសៃ រួមទាំងវិបសៃរបស់ស្ថាប័នព័ត៌មាន ដែលបង្កឱ្យមានការភ័យខ្លាចចំពោះការបំបែកផ្លូវ ការបិទសំឡេង និងការរាយការណ៍រិះគន់។

ប្រជាពលរដ្ឋខ្លាចមិនហ៊ាននិយាយប្រឆាំងនឹងរបបកាន់អំណាច។ យោងតាមការសិក្សាថ្មីៗរបស់មជ្ឈមណ្ឌលអាស៊ី (Asiacenter) មានការលើកឡើងថា បុគ្គលម្នាក់ៗបានឈានថយក្រោយមួយជំហានពីការចែករំលែកទស្សនៈនយោបាយផ្ទាល់ខ្លួនតាមអ៊ិនធឺណិត ឬចូលរួមក្នុងព្រឹត្តិការណ៍នយោបាយ ហើយផ្ទុយទៅវិញ ពួកគេចូលចិត្តអាន ឬស្តាប់ខ្លឹមសារនយោបាយ ពីព្រោះពួកគេខ្លាចមានបញ្ហាជាមួយអាជ្ញាធរកម្ពុជា ដែលបានបង្កើនការត្រួតពិនិត្យលើមជ្ឈដ្ឋានអនឡាញយ៉ាងកំរោល។

យោងតាមរបាយការណ៍ឃ្លាំមើលសេរីភាពជាមូលដ្ឋាននៅកម្ពុជារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅក្នុងឆ្នាំ ២០២០ មានការរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិដោយរាជរដ្ឋាភិបាលចំនួន១០៨ ករណី។ ក្នុងចំណោមករណីទាំងនោះ ៥៧ ករណី (៥៣%) បានកើតឡើងតាមអនឡាញ[24]។ របាយការណ៍នេះបានលើកឡើងថា និន្នាការនេះមានភាពស៊ីសង្វាក់គ្នាក្នុងរយៈពេល៣ ឆ្នាំចុងក្រោយនេះ ដែលក្នុងនោះអ្នកតបសម្ភាសន៍ចំនួន ៨៣% (ឆ្នាំ២០១៩), ៧៣% (ឆ្នាំ២០១៨), ៦៩% (ឆ្នាំ២០១៧) មានការប្រុងប្រយ័ត្នចំពោះសុវត្ថិភាពផ្ទាល់ខ្លួន នៅពេលផ្ញើ ឬចែករំលែកព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។ ថ្មីៗនេះ ក្នុងឆ្នាំ២០២២ របាយការណ៍របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដែលបានសម្ភាសន៍អ្នកសារព័ត៌មានបុរសចំនួន១៥ នាក់ និងស្ត្រីចំនួន៦ នាក់ បានបង្ហាញថា អ្នកសារព័ត៌មានចំនួន៦០% បានប្រឈមមុខនឹងការគំរាមកំហែងដោយពាក្យសំដីទាក់ទងនឹងការងាររបស់ពួកគេ។ ការសិក្សាមួយផ្សេងទៀតបានកត់សម្គាល់ថា ហ្វេសប៊ុកគឺជាវេទិកាអនឡាញដែលត្រូវបានតាមដានឈ្លបយកការណ៍ច្រើនជាងគេ ដោយមានការរឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិចំនួន៤៦ ករណី ត្រូវបានរាយការណ៍ បន្ទាប់មកតិកតុក (៨) និងយូធូប (៧)[25]។

## សេរីភាពក្នុងការទទួលបានព័ត៌មាន

ស្របតាមស្តង់ដារ និងគោលការណ៍សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងការទទួលបានព័ត៌មាន, ច្បាប់ និងលិខិតគតិយុត្តិមួយចំនួនរបស់កម្ពុជា បានធានាសិទ្ធិទទួលបានព័ត៌មាន (A2I)។ បទប្បញ្ញត្តិចំនួនបីនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នផ្តល់នូវការចង្អុលបង្ហាញអំពីសិទ្ធិដែលត្រូវការពារ "ក្នុងការទទួលបានព័ត៌មានប្រកបដោយគុណភាពខ្ពស់ និងត្រឹមត្រូវដែលកាន់កាប់ដោយរដ្ឋាភិបាលកម្ពុជា និងស្ថាប័នសាធារណៈផ្សេងទៀត" ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ មាត្រា៥ នៃច្បាប់ស្តីពីរបបសារព័ត៌មានទទួលស្គាល់ "សិទ្ធិទទួលបានព័ត៌មាននៅក្នុងកំណត់ត្រាដែលកាន់កាប់ដោយរដ្ឋាភិបាល។ មាត្រា១៣ នៃច្បាប់ស្តីពីបណ្ណសារឆ្នាំ២០០៥ ចែងថា៖ បណ្ណសារសាធារណៈ ដែលជាឯកសារបោះពុម្ពផ្សាយ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ដោយសាធារណជនសម្រាប់ការ

---

[24]Cited in https://asiacentre.org/wp-content/uploads/Internet-Freedoms-in-Cambodia-A-Gateway-to-Control.pdf

[25] Internet-Freedoms-in-Cambodia-A-Gateway-to-Control.pdf

ស្រាវជ្រាវ និងពិគ្រោះយោបល់ជាព័ត៌មានដែលមិនមានការរឹតបន្តឹង។ សកម្មភាពបណ្ណាសារសាធារណៈផ្សេងទៀតត្រូវអនុញ្ញាតឱ្យស្រាវជ្រាវបានរយៈពេល២០ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃឯកសារ ឬគិតចាប់ពីថ្ងៃបញ្ចប់សំណុំរឿង ឬក្នុងករណីពិសេសដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់នេះ[26]។ ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននៅតែស្ថិតក្នុងសេចក្តីព្រាងនៅឡើយ គិតត្រឹមចុងឆ្នាំ២០២១ ចាប់តាំងពីសេចក្តីព្រាងដំបូងត្រូវបានធ្វើឡើងនៅឆ្នាំ២០០៧ ។

ទោះជាយ៉ាងណានេះក្តី សេរីភាពក្នុងការទទួលបានព័ត៌មាននៅតែជាបញ្ហាប្រឈមដ៏ធំ។ ការសិក្សាស្រាវជ្រាវនាពេលថ្មីៗដែលរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ជាមួយអ្នកសារព័ត៌មាន បានបង្ហាញថា អ្នកសារព័ត៌មានកំពុងធ្វើការក្នុងបរិយាកាសកាន់តែពិបាកខ្លាំងឡើង ជាពិសេសពួកគេជួបការលំបាក ពាក់ព័ន្ធនឹងការទទួលបានព័ត៌មានពីប្រភពសាធារណៈ។ ខណៈអាជ្ញាធរបានអនុម័តច្បាប់ដែលហាក់ដូចជារារាំងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ អាជ្ញាធរបានពន្យារពេលបញ្ចប់ច្បាប់ថ្មីដូចបានសន្យា ដែលនឹងអនុញ្ញាតឱ្យអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយទទួលបានព័ត៌មានផ្លូវការ។

# ឯកជនភាព

## ប្រកាសអន្តរក្រសួងលេខ១៧០[27]

ប្រកាសនេះត្រូវបានអនុវត្តចំពេលដែលមានបរិយាកាសតឹងរ៉ឹងនៃការត្រួតពិនិត្យវេទិកាអនឡាញ ក្នុងអំឡុងពេលបោះឆ្នោត ដូចជាការបិទវិបសៃដែលគាំទ្រលទ្ធិប្រជាធិបតេយ្យជាដើម។ ប្រកាសដំបូងនេះអនុញ្ញាតឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការត្រួតពិនិត្យការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។ បទប្បញ្ញត្តិនេះកំណត់គោលដៅផ្ទាល់លើការបោះពុម្ពនៅលើវិបសៃ និងបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គម នៅក្នុងលំហអ៊ិនធឺណិតកម្ពុជា។ យោងតាមប្រការ៦ ក្រសួងព័ត៌មានត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងព័ត៌មានអនឡាញដែលបានបោះពុម្ពផ្សាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក និង "ចាត់វិធានការ" ប្រឆាំងនឹងការបោះពុម្ពផ្សាយខុសច្បាប់។

---

26 https://apiinstitute.org/uploads/Handbooks_Info%20Materials/Access%20to%20Information/Access%20to%20Information%20in%20Southeast%20Asia%20and%20Cambodia%20-%202010.pdf

27 សេរីភាពអ៊ិនធឺណិតនៅកម្ពុជា៖ ច្រកទ្វារ ដើម្បីត្រួតពិនិត្យ (asiacentre.org)

ខណៈប្រកាសអន្តរក្រសួងជារឿយៗត្រូវបានគេហៅថា ច្បាប់ប្រឆាំងនឹង "ព័ត៌មានក្លែងក្លាយ" របស់ប្រទេសកម្ពុជា ប្រកាសបែបនេះកម្រត្រូវបានគេប្រើ ដើម្បីផ្តន្ទាទោសចំពោះអំពើនៃការផ្សព្វផ្សាយព័ត៌មានមិនពិត។ ផ្ទុយទៅវិញ ប្រកាសបែបនេះត្រូវបានប្រើប្រាស់ជាយុត្តិកម្មសម្រាប់ការស៊ើបការណ៍តាមឌីជីថលរបស់រដ្ឋាភិបាល។

## ច្រកទ្វារអ៊ិនធឺណិតជាតិ[28]

អនុក្រឹត្យនេះបង្កើនសមត្ថភាពតាមដានច្រើនក្រាស់ក្រៃលើសកម្មភាពអ្នកប្រើប្រាស់ ដោយសារប្រតិបត្តិករច្រកផ្ទារនឹងរាយការណ៍អំពីការសង្កេតរបស់ខ្លួនលើការប្រើប្រាស់អិនធឺណិត ជូនទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ស្រដៀងគ្នានឹងប្រកាសអន្តរក្រសួងដែរ ច្បាប់នេះមានទិសដៅសម្រួលឱ្យរដ្ឋធ្វើការស៊ើបការណ៍តាមអនឡាន ជាជាងការដាក់ទោសទណ្ឌបទល្មើសតាមអនឡាញ។ ដូច្នេះ គោលនយោបាយថ្មីនេះ គឺជាឧបករណ៍ដ៏មានសក្តានុពលខ្លាំងបំផុតប្រឆាំងនឹងការសម្តែងមតិតាមអនឡាញ និងសិទ្ធិក្នុងការរក្សាឯកជនភាព។

មាត្រា៦ នៃច្បាប់នេះពិពណ៌នាអំពីមុខងារ និងភារកិច្ចរបស់ប្រតិបត្តិករច្រកទ្វារអិនធឺណិត។ ទាំងនេះរាប់បញ្ចូលទាំងការគ្រប់គ្រងសេវាតភ្ជាប់ និងសេវាអិនធឺណិត។ ដោយសារបទប្បញ្ញត្តិមិនច្បាស់លាស់ និងទូលំទូលាយពេក មាត្រានេះអនុញ្ញាតឱ្យរដ្ឋាភិបាលបិទខ្ទប់ការចូលទៅកាន់វិបសៃដែលផ្សព្វផ្សាយទស្សនៈរិះគន់រដ្ឋប្រឆាំងរដ្ឋាភិបាល ដោយដាក់ស្លាកវាថាជាព័ត៌មានដែលគំរាមកំហែងដល់សណ្តាប់ធ្នាប់ ឬសុវត្ថិភាពសង្គម។
មាត្រា១២ (ការប្រមូលចំណូល សុវត្ថិភាព និងការការពារសណ្តាប់ធ្នាប់សាធារណៈ) ក៏តម្រូវឱ្យប្រតិបត្តិករច្រកទ្វារអិនធឺណិត "[ធានា] សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់សង្គម ក៏ដូចជាការទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្ម"។ និយមន័យស្រពិចស្រពិល និងការវាយតម្លៃមិនច្បាស់លាស់នៃអ្វីដែលបង្កើតជាឧក្រិដ្ឋកម្ម ឬសកម្មភាពដែលគំរាមកំហែងដល់ "សណ្តាប់ធ្នាប់សង្គម សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់" អាចអនុញ្ញាតឱ្យមានការផ្តន្ទាទោសជាបន្តចំពោះសកម្មជនអនឡាញ និងអ្នកប្រើប្រាស់អិនធឺណិត ក្រោមហេតុផលនយោបាយ។ អ្នកផ្តល់សេវាក៏ត្រូវតែជំរុញអ្នកប្រើប្រាស់ឱ្យបំពេញទម្រង់អនឡាញ និងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេផងដែរ - ការប្រមូលទិន្នន័យបែបនេះ ដោយគ្មានវិធានការការពារជាធរមានលើឯកជនភាពទិន្នន័យ អាចនាំឱ្យមានការប្រើប្រាស់ទិន្នន័យ ដើម្បីស៊ើបការណ៍ និងតាមដានសកម្មភាពតាមអិនធឺណិត។ ដោយសារការតាមដានបែបនេះកើតមានជាងធម្មតារួចហើយនៅក្នុងប្រទេសកម្ពុជា ច្រកទ្វារអិនធឺណិតនេះធ្វើឱ្យស្ថានភាពសេរីភាពអិនធឺណិត និងស្វ័យពិរុទ្ធកាន់តែអាក្រក់ថែមទៀត។

---

[28] សេរីភាពអ៊ិនធឺណិតនៅកម្ពុជា៖ ច្រកទ្វារ ដើម្បីត្រួតពិនិត្យ (asiacentre.org)

នៅក្រោមមាត្រា១៤ ប្រតិបត្តិករច្រកទ្វារត្រូវបានតម្រូវឱ្យរក្សាទុកទិន្នន័យ និងផ្តល់របាយការណ៍ស្ថានភាពជាប្រចាំដល់អាជ្ញាធរ។ ការផ្ទុកឯកសារបច្ចេកទេស អាសយដ្ឋាន IP និងការកំណត់អត្តសញ្ញាណផ្លូវចរាចរណ៍តាមរយៈច្រកទ្វារអ៊ិនធឺណិតរយៈពេល១២ ខែ អនុញ្ញាតឱ្យប្រតិបត្តិករពិនិត្យតាមដានសកម្មភាពរបស់អ្នកប្រើប្រាស់។

## ករណីចាប់ពិរុទ្ធ និងស៊ើបការណ៍តាមអ៊ិនធឺណិត ដែលបានរាយការណ៍

ករណីចាប់ពិរុទ្ធ និងស៊ើបការណ៍តាមអ៊ិនធឺណិតមួយចំនួនត្រូវបានរាយការណ៍នៅក្នុងប្រទេសកម្ពុជាក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះ។ នៅថ្ងៃបោះឆ្នោត ថ្ងៃទី២៧ និង២៨ ឆ្នាំ ២០១៨ វិបសៃព័ត៌មានឯករាជ្យចំនួន១៥ រួមមានដូចជា សំឡេងសហរដ្ឋអាមេរិក ផ្នែកភាសាខ្មែរ វិទ្យុអាស៊ីសេរីផ្នែកភាសាខ្មែរ សំឡេងប្រជាធិបតេយ្យ វិទ្យុវ៉ាយ៉ូអេហ្វអឹម វិបសៃ Monorom.info និងវិបសៃព័ត៌មានរបស់បណ្តាញឯករាជ្យដើម្បីយុត្តិធម៌សង្គម ត្រូវបានបិទខ្ទប់ដោយអ្នកផ្តល់សេវាអ៊ិនធឺណិត តាមរយៈការបញ្ជាពីអាជ្ញាធររដ្ឋាភិបាល។

ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២ ទិន្នន័យរបស់ OONI បានបញ្ជាក់អះអាងពីវិបសៃចំនួន៤៣ ដែលត្រូវបានបិទ ហើយវិបសៃទាំង៤៣នេះត្រូវបានចាប់ពិរុទ្ធដោយ DNS ដែលភាគច្រើនដោយក្រុមហ៊ុនវៀតថែល (ខេមបូឌា) ភីធីអ៊ី អិលធីឌី (AS38623) និងក្រុមហ៊ុន S.I Group (AS38623)។ វិបសៃទាំងនេះរាប់បញ្ចូលទាំង៖ www.khmer.cambodiadaily.com, www.phnompenhpost.com, www.almanar.com.lb, www.samesexmarriage.com, www.appzplanet.com, www.888casino.com, www.carnivalcasino.com និង www.casino.com,... វិបសៃមួយទៀត ត្រូវបានចាត់ទុកថា ត្រូវបានចាប់ពិរុទ្ធដោយការប្រើប្រាស់ការបិទខ្ទប់ https របស់ខ្លួន។ គេហទំព័ររបស់វិបសៃនេះគឺ៖ www.worldlingo.com.

## ការពិនិត្យលើការចាប់ពិរុទ្ធតាមអ៊ិនធឺណិតនៅកម្ពុជា

ក្រុមអ្នកសង្កេតបើកចំហនៃការជ្រៀតជ្រែកបណ្តាញ (OONI) ដោយសហការជាមួយ គម្រោង Sinar Project និង វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ បានធ្វើការសិក្សាស្រាវជ្រាវអំពីការចាប់ពិរុទ្ធលើអ៊ិនធឺណិតនៅកម្ពុជា។ ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងឈ្វេងយល់ថា តើហេតុការណ៍ចាប់ពិរុទ្ធបានកើតឡើងនៅកម្ពុជា ដែរឬទេ និងក្នុងកម្រិតណា ក្នុងអំឡុងពេលសាកល្បង គិតចាប់ពីខែមករា ដល់ខែមិថុនាឆ្នាំ២០២២។

ផ្នែកខាងក្រោម បង្ហាញពីវិធីសាស្ត្រ និងលទ្ធផលរកឃើញសំខាន់ៗនៃការស្រាវជ្រាវនេះ។

## វិធីសាស្ត្រ

ក្នុងការព្យាយាមកំណត់ហេតុការណ៍ចាប់ពិរុទ្ធលើអិនធឺណិតដែលអាចមាននៅក្នុងប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវនេះបានអនុវត្តវិធីសាស្ត្រដូចខាងក្រោម៖

- ពិនិត្យឡើងវិញលើបញ្ជីតេស្តរបស់ Citizen Lab's Cambodia;
- អនុវត្តការវាស់វែងបណ្តាញរបស់ OONI និង
- ធ្វើការវិភាគទិន្នន័យ។

បញ្ជី URLs ដែលពាក់ព័ន្ធ និងចូលប្រើជាទូទៅក្នុងប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងដោយ Citizen Lab ក្នុងគោលបំណងជួយសម្រួលដល់អ្នកស្រាវជ្រាវវាស់ស្ទង់បណ្តាញ ក្នុងការពិនិត្យពីលទ្ធភាពចូលប្រើប្រាស់ពួកវានៅក្នុងប្រទេសកម្ពុជា។ ជាផ្នែកមួយនៃការសិក្សានេះ បញ្ជី URLs នេះត្រូវបានពិនិត្យឡើងវិញ ដើម្បីបញ្ចូល URLs បន្ថែម - រួមជាមួយ URLs ផ្សេងទៀតដែលត្រូវបានចូលប្រើជាទូទៅនៅជុំវិញពិភពលោក និងត្រូវបានសាកល្បងសម្រាប់ការបិទខ្ទប់ដោយផ្អែកលើតេស្តសុហ្វវែរដោយឥតគិតថ្លៃរបស់ OONI ។ URL សរុបចំនួន១៩១ មកពីប្រទេសកម្ពុជាត្រូវបានបន្ថែម។ ការធ្វើតេស្តបែបនេះត្រូវបានរៀបចំដំណើរការពីទីតាំងខ្ពស់នៅមូលដ្ឋានក្នុងប្រទេសកម្ពុជា ហើយពួកគេក៏បានពិនិត្យដែរថា តើប្រព័ន្ធដែលទទួលខុសត្រូវចំពោះការចាប់ពិរុទ្ធ ការស៊ើបការណ៍ និងការជ្រែកចរាចរណ៍ មានវត្តមាននៅក្នុងបណ្តាញដែលបានសាកល្បងដែរឬអត់។ នៅពេលដែលទិន្នន័យនៃការវាស់វែងបណ្តាញត្រូវបានប្រមូលពីការធ្វើតេស្តទាំងនេះ ទិន្នន័យត្រូវបានដំណើរការ និងវិភាគជាបន្តបន្ទាប់ដោយផ្អែកលើសំណុំវិធីសាស្ត្រស្វ័យពិសោធន៍សម្រាប់ការរាវរកឱ្យឃើញការចាប់ពិរុទ្ធលើអិនធឺណិត និងការជ្រែកចរាចរណ៍។

## រយៈពេលសាកល្បងសម្រាប់ការសិក្សាស្រាវជ្រាវនេះបានចាប់ផ្តើមពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២។

# លទ្ធផលរកឃើញ

## ប្រភេទវិបសៃ

OONI បានធ្វើចំណាត់ថ្នាក់វិបសៃជា៣២ ប្រភេទផ្សេងៗគ្នា សម្រាប់ការឃ្លាំមើលការចាប់ពិរុទ្ធលើអិនធឺណិត។

| ល.រ | ពិពណ៌នាប្រភេទ | កូដថ្មី |
|---|---|---|
| ១ | គ្រឿងស្រវឹង និងគ្រឿងញៀន | ALDR |
| ២ | សាសនា | REL |
| ៣ | អាសអាភាស | PORN |
| ៤ | ការស្លៀកពាក់ស្រើបស្រាល | PROV |
| ៥ | ការរិះគន់ខាងនយោបាយ | POLR |
| ៦ | បញ្ហាសិទ្ធិមនុស្ស | HUMR |
| ៧ | បរិស្ថាន | ENV |
| ៨ | ភេរវកម្ម និងពួកសកម្មប្រយុទ្ធ | MILX |
| ៩ | វាចាព្យាបាទ | HATE |
| ១០ | សារព័ត៌មាន | NEWS |
| ១១ | ការអប់រំផ្លូវភេទ | XED |
| ១២ | សុខភាពសាធារណៈ | PUBH |
| ១៣ | ល្បែងស៊ីសង | GMB |
| ១៤ | ឧបករណ៍អនាមិក និងឧបករណ៍បញ្ចៀសការចាប់ពិរុទ្ធ | ANON |
| ១៥ | ការស្វែងរកដៃគូស្នេហាតាមអនឡាញ | DATE |

| | | |
|---|---|---|
| ១៦ | បណ្ដាញសង្គម | GRP |
| ១៧ | អ្នកស្រលាញ់ភេទដូចគ្នា | LGBT |
| ១៨ | ការចែករំលែកឯកសារ | FILE |
| ១៩ | ឧបករណ៍ហែកចូល | HACK |
| ២០ | ឧបករណ៍ទំនាក់ទំនង | COMT |
| ២១ | ការចែករំលែកប្រព័ន្ធផ្សព្វផ្សាយ | MMED |
| ២២ | វេទិកាបាហនិក និងប្លក់ | HOST |
| ២៣ | ក្បាលម៉ាស៊ីនស្វែងរក | SRCH |
| ២៤ | ហ្គេម | GAME |
| ២៥ | វប្បធម៌ | CULTR |
| ២៦ | សេដ្ឋកិច្ច | ECON |
| ២៧ | រដ្ឋាភិបាល | GOVT |
| ២៨ | ពាណិជ្ជកម្មអេឡិចត្រូនិច | COMM |
| ២៩ | គ្រប់គ្រងមាតិកា | CTRL |
| ៣០ | អង្គការអន្តររដ្ឋាភិបាល | IGO |
| ៣១ | ខ្លឹមសារផ្សេងៗ | MISC |

## ចំនួននៃការធ្វើតេស្តវិបសៃតាមប្រភេទ

រហូតដល់ចុងខែមិថុនា វិបសៃចំនួន១៧៣០ (វិបសៃអន្តរជាតិ និងវិបសៃអន្តរជាតិ) មកពីប្រភេទផ្សេងៗគ្នា មានឈ្មោះនៅក្នុងបញ្ជីតេស្តរបស់ Citizen Lab និងវាយបញ្ចូលឈ្មោះវិបសៃប្រចាំឆ្នាំនៅក្នុងឧបករណ៍ OONI ដោយផ្ទាល់សម្រាប់ការពិនិត្យតាមដានភាពងាយស្រួលនៃវិបសៃនៅក្នុងបណ្ដាញកម្ពុជាដោយ ដោយប្រើឧបករណ៍ OONI ដែលកំពុងដំណើរការ។ ប្រភេទវិបសៃត្រូវបានដាក់ជាក្រុម៖ រដ្ឋាភិបាល សេដ្ឋកិច្ច ការចែករំលែកឯកសារ អ្នកស្រឡាញ់ភេទដូចគ្នា ព័ត៌មាន បណ្ដាញសង្គម សិទ្ធិមនុស្ស។ល។ ក្រាហ្វិកខាងក្រោមបង្ហាញពីចំនួនគេហទំព័រតាមប្រភេទវិបសៃ។




## ការរាប់ការវាស់វែងនៃការដំណើរការ OONI

ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោម OONI Probe បានបង្ហាញថា ការធ្វើតេស្តនេះបានដំណើរការការវាស់វែងចំនួន២៨៩.៣៥៧ ក្នុងអំឡុងពេលរាយការណ៍។ ក្នុងចំណោមការវាស់វែងទាំងនោះ មានការវាស់វែងចំនួន ៩៦.៤២% ស្មើនឹង២៧៨.៩៨៥ ត្រូវបានដំណើរការដោយជោគជ័យ ដោយទទួលបានលទ្ធផលជាវិជ្ជមាន ដែលបង្ហាញថា ពុំមានការបិទខ្ទប់ ឬការហែកចូលទេ និងមានការរាប់ឃើញថា ការវាស់វែងចន្ទួន០.៧១% ស្មើនឹង

២០៦៧ ដំណើរការមិនជោគជ័យ។ ការវាស់វែងដែលនៅសល់ចំនួន២.៨៧% ឬស្មើនឹង៨៣០៥ ត្រូវបានកត់ត្រាជាការរាប់មិនប្រក្រតី។ ក្រាហ្វ និងទិន្នន័យខាងក្រោមគឺជាប្រវែងនៃការវាស់វែង និងលទ្ធផលចរាចរណ៍ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២២។




| ការរាប់វង្វាស់ពីការដំណើរការ OONI | | | | |
|---|---|---|---|---|
| | | | | |
| ខែ | ការរាប់វង្វាស់ | ការរាប់ដែលល្អ | ការរាប់ដែលមិនប្រក្រតី | ការរាប់ដែលបរាជ័យ |
| មករា | ៤៥៨០៦ | ៤៣៩០៨ | ១៣៦៤ | ៥៣៤ |

| | | | | |
|---|---|---|---|---|
| កុម្ភៈ | ៥៤៧៩៥ | ៥២៤២១ | ១៥៨២ | ៧៩២ |
| មីនា | ២៦០៤៣ | ២៤៤៤២ | ១៤៤៨ | ១៥៣ |
| មេសា | ៣៧៣៥២ | ៣៦២០៤ | ៩៨២ | ១៦៦ |
| ឧសភា | ៦៤៥១៦ | ៦២៦៧៩ | ១៥៥៨ | ២៧៩ |
| មិថុនា | ៦០៨៤៥ | ៥៩៣៣១ | ១៣៧១ | ១៤៣ |
| **សរុប** | ២៨៩៣៥៧ | ២៧៨៩៨៥ | ៨៣០៥ | ២០៦៧ |
| **សរុប (%)** | **១០០%** | **៩៦.៤២%** | **២.៨៧%** | **០.៧១%** |



## លទ្ធផលនៃវិបសៃដែលបានចាប់ពិរុទ្ធ

ជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវនេះ រង្វាស់បណ្ដាញត្រូវបានប្រមូលតាមរយៈតេស្តសុហ្វវែរ OONI Probe ដោយរយៈពេលនៃការធ្វើតេស្ត គិតចាប់ពីខែមករា ដល់ខែមិថុនា។ លទ្ធផលបានបង្ហាញថា ULRs/វិបសៃចំនួន ៤៣ ក្នុងចំណោម ULRs/វិបសៃចំនួន១៧៣០ ត្រូវបានបិទខ្ទប់ ឬហែកចូល។ ក្រៅពីនេះ លទ្ធផលនៃការវិភាគតាមបែបវិធីសាស្រ្តស្វ័យពិសោធន៍បានរាយការណ៍ថា គេហទំព័រចំនួន៤៣ ត្រូវបានបិទខ្ទប់ដោយការអុកឡុកពីសំណាក់ DNS តាមរយៈការបង្វែរទិសទៅកាន់អាសយដ្ឋាន IPចំនួន២៖ ['10.10.10.1'] និង['36.37.242.94']។




ព័ត៌មានលំអិតនៃវិបសៃដែលពេញនិយមក្នុងស្រុកក្នុងចំណោមវិបសៃចំនួន៤៣ត្រូវបានចាប់ពិរុទ្ធ/ហែកចូលដោយ DNS រួមទាំងកាលបរិច្ឆេទ និងលេខប្រព័ន្ធស្វយ័ត(ASN)។ វិបសៃទាំងនេះត្រូវបានចាត់ថ្នាក់តាមប្រភេទ ៖ ព័ត៌មាន មនុស្សស្រឡាញ់ភេទដូចគ្នា ល្បែងស៊ីសង ក្បាលម៉ាស៊ីនស្រាវជ្រាវ និងសុខភាពសាធារណៈ ក្នុងចំណោមវិបសៃជាតិ និងអន្តរជាតិចំនួន៤៣ ជាការគួរឱ្យចាប់អារម្មណ៍ ដែលប្រជាពលរដ្ឋកម្ពុជាអាចចូលមើលដែលត្រូវបានចាត់ទុកថា ត្រូវបានបិទយ៉ាងហ្មឹងហ្មាត់ ត្រូវបានបង្ហាញខាងក្រោម៖

- ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន៖ www.khmer.cambodiadaily.com និង www.almanar.com.lb ត្រូវបានបិទខ្ទប់ដោយ S.I Group ដែលមានលេខប្រព័ន្ធស្វយ័ត AS131207 នៅថ្ងៃទី២៦ ខែកុម្ភៈ និងថ្ងៃទី២ ខែមីនា និងវ៉ិបសៃមួយទៀតគឺ www.phnompenhpost.com ត្រូវបានបិទខ្ទប់ដោយ S.I Group ដែលមានលេខប្រព័ន្ធស្វយ័ត AS131207 នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២២។
- សេវារកគូស្នេហាតាមអនឡាញ៖ www.samesexmarriage.com ត្រូវបានបិទខ្ទប់ដោយ S.I Group ដែលមានលេខប្រព័ន្ធស្វយ័ត AS131207 នៅថ្ងៃទី១០, ១៥ និង១៨ ខែមីនា ឆ្នាំ២០២២។
- ការចែករំលែកឯកសារ៖ www.appzplanet.com ត្រូវបានបិទខ្ទប់ដោយ CamGSM ដែលមានលេខប្រព័ន្ធស្វយ័ត AS17976 នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ និង www.serials.ws ត្រូវបានបិទខ្ទប់ដោយ S.I Group ដែលមានលេខប្រព័ន្ធស្វយ័ត AS1312074 នៅថ្ងៃទី១៣ និង២២ ខែមីនា ឆ្នាំ២០២២។
- ល្បែងស៊ីសង៖ www.carnivalcasino.com, www.888casino.com, www.casino.com, និង www.casinotropez.com ត្រូវបានបិទខ្ទប់ដោយក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត វៀតថែល (ខេមបូឌា) ភីធីអី.អិលធីឌី ដែលមានលេខប្រព័ន្ធស្វយ័ត AS38623 និងដោយ S.I Group ដែលមានលេខប្រព័ន្ធស្វយ័ត AS131207។

**តារាងខាងក្រោមបង្ហាញលម្អិតអំពីវ៉ិបសៃ ដែលត្រូវបានបិទខ្ទប់តាមរយៈវិធីសាស្រ្តអុកឡុករបស់ប្រព័ន្ធគ្រប់គ្រងឈ្មោះគេហទំព័រ៖**

| ល.រ | ប្រភេទ | គេហទំព័រ | ចំនួនសរុប |
|---|---|---|---|
| ១ | សារព័ត៌មាន | www.phnompenhpost.com | ១ |
| | | khmer.cambodiadaily.com | ១ |
| | | www.almanar.com.lb | ១ |

| | | | |
|---|---|---|---|
| | ការស្វែងរកដៃគូស្នេហាតាមអនឡាញ | adultfriendfinder.com | ១ |
| ២ | ការចែករំលែកសំណុំឯកសារ | www.appzplanet.com | ១ |
| | | www.serials.ws | ១ |
| ៣ | ល្បែងស៊ីសង | www.888casino.com | ១ |
| | | www.carnivalcasino.com | ១ |
| | | www.casino.com | ១ |
| | | www.casinotropez.com | ១ |
| | | www.europacasino.com | ១ |
| | | www.partypoker.com | ១ |
| | | www.sportsinteraction.com | ១ |
| ៤ | ឧបករណ៍អនាមិក និងឧបករណ៍បញ្ចៀស | guardster.com | ១ |
| ៦ | ការអប់រំផ្លូវភេទ | www.teenhealthfx.com | ១ |
| ៧ | ឧបករណ៍ហែកចូល | www.blackhat.be | ១ |

| | | | |
|---|---|---|---|
| ៨ | **ចាហានិក** | pingomatic.com | ១ |
| | | technorati.com | ១ |
| ៩ | ក្បាលម៉ាស៊ីនស្វែងរក | www.mamma.com | ១ |
| ១០ | អាសអាភាស | alt.com | ១ |
| ១១ | អង្គការអន្តរដ្ឋាភិបាល | secure.friendfinder.com | ១ |
| | | www.anonymizer.com | ១ |
| | | mixi.jp | ១ |
| ១២ | ផ្សេងៗ | www.hrcr.org can't access | ១ |
| | | www.wetplace.com | ១ |
| | | apps.crowdtangle.com | ១ |
| | | coronavirus-map.com | ១ |
| | | www.samesexmarriage.ca | ១ |
| | | stubes.info - | ១ |

| | | | |
|---|---|---|---|
| | | www.kirivong.com | ៩ |
| | | www.ruf-ch.org | ៩ |
| | | dailystormer.name | ៩ |
| | | www.rotten.com | ៩ |
| | | anonnews.org | ៩ |
| | | moqavemat.ir | ៩ |
| | | veracrypt.codeplex.com | ៩ |
| | | www.fring.com | ៩ |
| | | www.pokerroom.com | ៩ |
| | | www.volcanomail.com | ៩ |
| | | www.nazi-lauck-nsdapao.com | ៩ |
| | | www.cnrp7.org | ៩ |
| | | www.ebuddy.com | ៩ |

| | | | |
|---|---|---|---|
| | | www.cannabis.info | ១ |
| ១៣ | សរុប | | ៤៣ |

## ទិដ្ឋភាពវែបសៃដែលត្រូវបានបិទខ្ទប់ដោយប្រើវិធីសាស្ត្រ HTTP

ក្រៅពីការបិទខ្ទប់ដោយ DNS URLs នៅក្នុងបញ្ជីខាងក្រោម បានជួបប្រទះបញ្ហាមួយចំនួនទាក់ទងនឹងការរុករកតាម HTTP។ វ៉ិបសៃតែមួយ (www.worldlingo.com) ត្រូវបានចាត់ទុកថា ត្រូវបានចាប់ពិរុទ្ធដោយសារថា *"អេចធីធីភី.ការតភ្ជាប់_ត្រូវបានបិទ" (http.connection_closed )* ចំនួន៩៥ ដង។

| គេហទំព័រ | ប្រភេទ | dns.confirmed | http.connection_closed | http.connection_reset | http.connection_timeout |
|---|---|---|---|---|---|
| www.worldlingo.com | សំណុំឯកសារ | 0 | ៩៥ | 0 | 0 |

## ការផ្ញើសារហេ័ស

លទ្ធផលនៃ OONI Probe ដំណើរការចាប់ពីខែមករាដល់ខែមិថុនា ឆ្នាំ២០២២ ការវាស់វែងលើហ្វេសប៊ុកចំនួន ២៩៦៧ ដង ការវាស់វែងតេឡេក្រាមចំនួន២៩៧៧ ការវាស់វែងវាត់អាប់២៩៦៥ និងការវាស់វែងស៊ីកណល់ចំនួន២៩៥៩ បង្ហាញថា វេទិកាទាំងនេះមិនត្រូវបានបិទខ្ទប់ពីអ្នកផ្ដល់សេវាអ៊ិនធឺណិតផ្សេងទៀតទេ។

| វ៉ិបសៃ | measurement_count | ok_count | Confirm_Count | anomaly_count | failure_count |
|---|---|---|---|---|---|
| ហ្វេសប៊ុក | ២៩៦៧ | ២៩៦១ | 0 | ៦ | 0 |
| តេឡេក្រាម | ២៩៧៧ | ២៩៥០ | 0 | ២៧ | 0 |

| | | | | | |
|---|---|---|---|---|---|
| វ៉ាត់អាប់ | ២៩៦៥ | ២៩៤១ | ០ | ២៤ | ០ |
| ស៊ីកណល់ | ២៩៥៩ | ២៩៤៦ | ០ | ១៣ | ០ |

## ឧបករណ៍បញ្ចៀស

ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោម OONI Probe បានបង្ហាញថា ដំណើរការតេស្តវង្វាស់ PSiphon ចំនួន ២៩៨៧ និង Tor ចំនួន៣៧ មិនត្រូវបានបិទខ្ទប់ដោយការតភ្ជាប់បណ្តាញណាមួយទេ។

| ការបញ្ចៀស | **measurement_count** | **measurement_ok** | **anomaly_count** | **failure_count** |
|---|---|---|---|---|
| **PSIPHON** | ២៩៨៧ | ២៩៤៦ | ៤១ | ០ |
| **Tor** | ៣៧ | ៣៣ | ៤ | ០ |

# ការសន្និដ្ឋាន និងអនុសាសន៍

វិបសៃព័ត៌មាន និងវិបសៃផ្សេងទៀតត្រូវបានបិទខ្ទប់តាមកាលកំណត់នៅក្នុងប្រទេសកម្ពុជា ជាពិសេសវិបសៃដែលផ្សព្វផ្សាយព័ត៌មានដែលអាចយល់ឃើញថាជាការគំរាមកំហែងដល់រដ្ឋាភិបាលដែលកំពុងកាន់អំណាច។ ករណីមួយចំនួននៃការចាប់ពិរុទ្ធ និងការស៊ើបការណ៍លើអ៊ិនធឺណិតត្រូវបានរាយការណ៍នៅក្នុងកម្ពុជា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ នៅថ្ងៃបោះឆ្នោត ទី២៧ និង២៨ ខែកក្កដា ឆ្នាំ២០១៨ គិតចាប់ពីខែកក្កដា ឆ្នាំ២០១៨ ដល់ខែកុម្ភៈ ឆ្នាំ២០២២ វិបសៃជាង១០០ត្រូវបានបិទខ្ទប់ដោយរដ្ឋាភិបាលកម្ពុជា។ ករណីភាគច្រើនបានកើតឡើងក្នុងអំឡុងពេលនៃការរំលាយគណបក្សប្រឆាំង គឺគណបក្សសង្គ្រោះជាតិ នៅក្នុងឆ្នាំ២០១៧ ការបោះឆ្នោតជាតិឆ្នាំ២០១៨ និងយុទ្ធនាការរបស់រដ្ឋាភិបាល ក្នុងការបិទល្បែងស៊ីសងតាមអនឡាញ និងល្បែងឆ្នោតខុសច្បាប់នៅក្នុងឆ្នាំ២០២១ និង២០២២។ ការបិទខ្ទប់ទាំងអស់ត្រូវបានធ្វើឡើងដោយអ្នកផ្តល់សេវាអ៊ិនធឺណិតតាមការបញ្ជាពីអាជ្ញាធររដ្ឋាភិបាល។

សេរីភាពសារព័ត៌មាន និងសេរីភាពអ៊ិនធឺណិតនៅកម្ពុជាកំពុងរងការគំរាមកំហែងកាន់តែខ្លាំង។ នៅក្នុងឆ្នាំ២០២ កម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេស "មិនសេរី"។ ប្រជាពលរដ្ឋខ្មែរ មិនហ៊ានបញ្ចេញទស្សនៈ ឬមតិតាមអនឡាញ ជាពិសេសអ្នកដែលរិះគន់រដ្ឋាភិបាល។ រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់ច្បាប់ និងលិខិតគតិយុត្តជាធរមាន ហើយបានបង្កើតច្បាប់ថ្មី ដើម្បីបង្កើនការជ្រៀតជ្រែក។ ការចាប់ពិរុទ្ធបានកើនឡើងយ៉ាងគំហុកនៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្នុងទម្រង់ផ្សេងៗគ្នា។ ការដាក់ចេញដោយបង្ខំ នូវវិធានការផ្លូវច្បាប់ និងមិនមែនផ្លូវច្បាប់ដោយរដ្ឋាភិបាលកម្ពុជាប្រឆាំងនឹងក្រុម ឬបុគ្គលដែលបានកំណត់ជាគោលដៅ បានរឹតត្បិតជាអវិជ្ជមានលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពអ៊ិនធឺណិត។

ទិន្នន័យរបស់ OONI បានបញ្ជាក់អះអាងពីវិបសៃចំនួន៤៣ ដែលត្រូវបានបិទខ្ទប់យ៉ាងតឹងរឹង ហើយវិបសៃទាំង៤៣ត្រូវបានចាប់ពិរុទ្ធដោយ DNS ដែលភាគច្រើនដោយក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត វៀតថែល (ខេមបូឌា) ភីធីអឹ.អិលធីឌី (AS38623) និង S.I Group (AS38623)។ ក្នុងចំណោមវិបសៃទាំងនេះ វិបសៃអន្តររដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ និងចែករំលែកសំណុំឯកសារ បានទទួលរងការវាយប្រហារ។ កត្តានេះបន្តបង្កការព្រួយបារម្ភ និងការព្រមានកាន់តែខ្លាំងអំពីសេរីភាពសារព័ត៌មាន សេរីភាពអ៊ិនធឺណិត និងការចាប់ពិរុទ្ធនៅកម្ពុជា។

ផ្អែកលើការវិភាគ និងលទ្ធផលរកឃើញនៅក្នុងរបាយការណ៍នេះ យើងសូមបញ្ជាក់ជាថ្មីលើការថ្កោលទោសដែលធ្វើឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា។ ដូច្នេះ យើងសូមផ្តល់អនុសាសន៍ ឱ្យរដ្ឋពិនិត្យ និងកែសម្រួលច្បាប់បច្ចុប្បន្ន និងនីតិកម្មដែលមិនទាន់បញ្ចប់ រួមទាំងអនុក្រឹត្យស្តីពីច្រកទ្វារអ៊ិនធឺណិតជាតិ និងវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមអ៊ិនធឺណិត និងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដើម្បីបញ្ចៀសការប្រើប្រាស់ពាក្យពេចន៍មិនច្បាស់លាស់ និងការរឹតត្បិតដែលទូលំទូលាយពេក។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍បន្ថែមទៀត ឱ្យរដ្ឋជានាថា នៅក្នុងការតាក់តែង និងការអនុវត្តច្បាប់របស់ខ្លួន រួមទាំងអនុក្រឹត្យរបស់នាយករដ្ឋមន្ត្រី ការរឹតត្បិតលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងការបង្កើតអង្គការ/សមាគម ត្រូវអនុលោមតាមការតម្រូវដ៏តឹងរឹងនៃមាត្រា១៩ (៣) និង២២ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។